ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 40

# ទ្រព្យវិនិយោគ

## Investment Property

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**



បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង“ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ”នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ចី គាយី**

## គោលបំណង

១ ស្តង់ដានេះគឺដើម្បីកំណត់នូវការធ្វើគណនេយ្យកម្មចំពោះទ្រព្យវិនិយោគ និងសេចក្តីតម្រូវ នៃការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធផ្សេងៗ ។

## វិសាលភាព

២ ស្តង់ដានេះនឹងត្រូវដាក់ឱ្យអនុវត្តក្នុងការទទួលស្គាល់ការវាស់វែង និងលាតត្រដាងព័ត៌មាន អំពីទ្រព្យវិនិយោគ។

៣ ក្នុងចំណោមស្តង់ដាផ្សេងទៀត ស្តង់ដានេះ អនុវត្តចំពោះការវាស់វែង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈភាគកម្មនៃទ្រព្យវិនិយោគ ដែលកាន់កាប់ក្រោមរូបភាពជាភតិសន្យាហិរញ្ញវត្ថុ និងអនុវត្តចំពោះការវាស់វែង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អតិបតីស្តីពីទ្រព្យវិនិយោគដែលផ្តល់ទៅភតិកៈក្រោមរូបភាពភតិសន្យាប្រតិបត្តិការមួយ។ស្តង់ដានេះមិនអនុវត្តចំពោះកិច្ចការដែលមានចែងនៅក្នុង ស.គ.អ.ក ១៧ ភតិសន្យា ទេ

(ក) ការចាត់ថ្នាក់ភតិសន្យាជាភតិសន្យាហិរញ្ញវត្ថុឬភតិសន្យាប្រតិបត្តិការ

(ខ) ការទទួលស្គាល់ចំណូលនៃភតិសន្យា ដែលបានមកពីទ្រព្យវិនិយោគ (សូមមើល ស.គ.អ.ក ១៨ ចំណូល)

(គ) ការវាស់វែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈ ស្តីពីអត្ថប្រយោជន៍នៃទ្រព្យដែលកាន់កាប់ ក្រោមរូបភាពភតិសន្យាប្រតិបត្តិការ។

(ឃ) ការវាស់វែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភតិបតី ស្តីពីការវិនិយោគពិត នៅក្នុង ភតិសន្យាហិរញ្ញវត្ថុ។

(ង) ការពិពណ៌នា អំពីប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់មកវិញ

(ច) ការបង្ហាញព័ត៌មានអំពីភតិសន្យាហិរញ្ញវត្ថុនិងភតិសន្យាប្រតិបត្តិ។

៤ ស្តង់ដានេះ មិនអនុវត្តចំពោះ ÷

(ក) ទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទិនទៅនឹងសកម្មភាពកសិកម្ម (សូមមើល ស.គ.អ.ក ៤១ *កសិកម្ម*) និង

(ខ) សិទ្ធិទៅលើរ៉ែខនិជ និងធនធានបម្រុងរ៉ែខនិជ ដូចជាប្រេង ឧស្ម័នធម្មជាតិនិងធនធានដែលមិនផលិតបានឡើងវិញ ប្រហាក់ប្រហែលផ្សេងៗទៀត។

## និយមន័យ

---

៥ ពាក្យស័ព្ទខាងក្រោមនេះ ត្រូវបានប្រើប្រាស់នៅក្នុងស្តង់ដានេះដោយ មានបញ្ជាក់ន័យដូចតទៅ ÷

***តម្លៃយោង*** **គឺជាចំនួនទឹកប្រាក់នៃទ្រព្យសកម្ម ដែលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។**

***ថ្លៃដើម*** **គឺជាចំនួនទឹកប្រាក់ នៃសាច់ប្រាក់ ឬ សាច់ប្រាក់ សមមូល ដែលបានបង់ ឬតម្លៃសមស្របនៃតម្លៃតបស្នងផ្សេងទៀត ដើម្បីទិញ ទ្រព្យសកម្មមួយនៅពេលទិញ ឬ នៅពេលសាងសង់ ឬ បើអាចអនុវត្តបាន**

ទឹកប្រាក់ នោះ ត្រូវដាក់បញ្ចូលក្នុងទ្រព្យសកម្ម នៅពេល ទទួលស្គាល់តាំងពីគ្រាដំបូង យោងទៅតាមតម្រូវការជាក់លាក់ នៃ ស.រ.ហ.អ ផ្សេងទៀត (ឧទាហរណ៍ ស.រ.ហ.អ.ក ២ ÷ ការទូទាត់ដោយផ្អែកលើបំណ្ណភាគហ៊ុន

*តម្លៃសមស្រប*គឺជាទឹកប្រាក់ ដែលទ្រព្យសកម្មមួយអាចត្រូវដោះដូរ ឬបំណុលដែលត្រូវទូទាត់រវាងភាគីដែលមានឆន្ទៈនិងយល់ដឹងនៅក្នុងប្រតិបត្តិការបើកចំហ។

*ទ្រព្យវិនិយោគ* គឺទ្រព្យ (ដី ឬអគារឬផ្នែកមួយនៃអគារឬទាំងពីរ) ដែលកាន់កាប់(ដោយម្ចាស់ ឬដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ ដើម្បីរកចំណូលតាមការជួល ឬ សម្រាប់ការបង្កើន ដើមទុន ឬ ទាំងពីរ ជាជាងសំរាប់ៈ

ក- ប្រើប្រាស់ក្នុងខ្សែផលិតកម្ម ឬ ផ្គត់ផ្គង់ទំនិញ ឬសេវា ឬសម្រាប់ប្រើប្រាស់រដ្ឋបាល។

ខ- សម្រាប់លក់នៅក្នុងសកម្មភាពធម្មតានៃអាជីវកម្ម។

*ទ្រព្យកាន់កាប់ដោយម្ចាស់* គឺជាទ្រព្យដែលកាន់កាប់ (ដោយម្ចាស់ ឬភតិកៈ ក្រោមភតិសន្យាហិរញ្ញវត្ថុ) សម្រាប់ប្រើប្រាស់ ក្នុងខ្សែផលិតកម្ម ឬ ផ្គត់ផ្គង់ទំនិញ ឬសេវាឬសម្រាប់ប្រើប្រាស់ក្នុងគោលបំណងរដ្ឋបាល។

៦ ភាគកម្មនៃទ្រព្យ ដែលកាន់កាប់ដោយភតិកៈ ក្រោមភតិសន្យាប្រតិបត្តិការមួយអាចត្រូវបានចាត់ថ្នាក់ជា ទ្រព្យវិនិយោគ បើសិនជាទ្រព្យនោះឆ្លើយតបទៅនឹងនិយមន័យនៃទ្រព្យវិនិយោគនោះ ហើយភតិកៈ ប្រើប្រាស់នូវវិធីសាស្ត្រតម្លៃសមស្រប ដែលចែងនៅក្នុង កថាខណ្ឌ ៣៣-៥៥ សម្រាប់ទ្រព្យសកម្ម ដែលត្រូវបានទទួលស្គាល់ ។ របៀបចាត់ថ្នាក់តាម

**វិធីជម្រើសនេះ ប្រព្រឹត្តទៅដោយឈរលើមូលដ្ឋានចាត់ថ្នាក់ តាមប្រភេទទ្រព្យនីមួយៗ។ ផ្ទុយទៅវិញ នៅពេលរបៀបចាត់ថ្នាក់នេះ ត្រូវបានជ្រើសរើសសម្រាប់ ភាគកម្មមួយបែបនៃទ្រព្យ ដែលបានរៀបចំឡើងក្រោមភតិសន្យាប្រតិបត្តិការនោះ ទ្រព្យទាំងអស់ដែល ចាត់ជាទ្រព្យវិនិយោគនឹងត្រូវកត់ត្រាក្នុងគណនេយ្យ ដោយប្រើប្រាស់នូវវិធីសាស្ត្រតម្លៃសមស្រប។ នៅពេល របៀបចាត់ថ្នាក់តាមវិធីជម្រើសនេះ ត្រូវបានគេជ្រើសយកភាគកម្មណាមួយ ដែលបានចាត់ថ្នាក់របៀបនេះ ត្រូវបញ្ចូលទៅក្នុងការលាតត្រដាងព័ត៌មានដែលតម្រូវដោយកថាខណ្ឌទី ៧៤ ដល់ ៧៨។**

៧ ទ្រព្យវិនិយោគ ត្រូវបានកាន់កាប់ដើម្បីទទួលបានថ្លៃជួល ឬដើម្បីបង្កើនមូលធន ឬដើម្បីទទួលបានទាំងពីរ។ ហេតុដូច្នេះ ទ្រព្យវិនិយោគ បានផលិតចេញនូវលំហូរសាច់ប្រាក់ដ៏ធំដោយឯកឯងច្រើនជាងទ្រព្យសកម្មដទៃទៀត ដែលគ្រប់គ្រងដោយអង្គភាព ។ កត្តានេះ វាជួយញែកទ្រព្យវិនិយោគឱ្យដាច់ចេញពីទ្រព្យដែល កាន់កាប់ដោយម្ចាស់ ។ ការផលិត ឬការផ្គត់ផ្គង់ទំនិញ ឬ សេវា (ឬក៏ការប្រើប្រាស់ទ្រព្យ សម្រាប់គោល បំណងរដ្ឋបាល) បានផលិតនូវលំហូរសាច់ប្រាក់ដែលអាចបញ្ចូល មិនត្រឹមតែ ទៅក្នុងទ្រព្យប៉ុណ្ណោះទេ ថែមទាំងទ្រព្យសកម្មដទៃទៀត ដែលប្រើប្រាស់នៅក្នុងខ្សែសង្វាក់ផលិតកម្ម ឬដំណើរការផ្គត់ផ្គង់។ ស.គ.អ.ក ១៦ *ទ្រព្យរោងចក្រនិងឧបករណ៍*អនុវត្តចំពោះទ្រព្យដែលកាន់កាប់ដោយម្ចាស់។

៨ ខាងក្រោមនេះ គឺជាឧទាហរណ៍ នៃទ្រព្យវិនិយោគ ៖

(ក) ដីធ្លី ដែលត្រូវរក្សាទុកសម្រាប់ការបង្កើនតម្លៃមូលធនរយៈពេលវែងជាជាងសម្រាប់ការលក់រយៈពេលខ្លីនៅក្នុងអំឡុងពេលធម្មតានៃជំនួញ។

(ខ) ដីធ្លី ដែលត្រូវរក្សាទុកសម្រាប់ការប្រើប្រាស់ គ្មានការគ្រោងទុកនាពេលអនាគត ។ (បើអង្គភាព មួយ មិនបានកំណត់ថា ខ្លួននឹងប្រើប្រាស់ដីធ្លីនេះ ជាទ្រព្យកាន់កាប់ដោយម្ចាស់ ឬសម្រាប់ការលក់រយៈពេលខ្លីក្នុងអំឡុងពេលធម្មតានៃអាជីវកម្មនោះទេដីធ្លីនឹងត្រូវចាត់ទុកថារក្សាទុកសម្រាប់ការបង្កើនតម្លៃមូលធន។)

(គ) អគារ ដែលជាកម្មសិទ្ធិរបស់អង្គភាពនោះ (ឬគ្រប់គ្រងដោយអង្គភាពនោះតាមភតិសន្យាហិរញ្ញវត្ថុ)និងដែលជួលឱ្យគេក្រោមភតិសន្យាប្រតិបត្តិការមួយ ឬច្រើន។

(ឃ) អគារទំនេរ ដែលត្រូវរក្សាទុកសម្រាប់ជួលឱ្យគេ ក្រោមភតិសន្យាប្រតិបត្តិការមួយ ឬ ច្រើន។

(ង) ទ្រព្យសកម្មដែលត្រូវបានកំពុងសាងសង់ ឬអភិវឌ្ឍនិសម្រាប់ប្រើប្រាស់នាពេលអនាគត ជាទ្រព្យវិនិយោគ។

៩ ខាងក្រោមនេះជាឧទាហរណ៍ នៃធាតុដែលមិនមែនជាទ្រព្យវិនិយោគ និងដូចនេះហើយ វាស្ថិតនៅក្រៅវិសាលភាពនៃស្តង់ដានេះ ÷

(ក) ទ្រព្យដែលត្រូវទុកសម្រាប់លក់នៅក្នុងអំឡុងពេលធម្មតានៃជំនួញ ឬនៅក្នុងដំណើរការសាងសង់ ឬអភិវឌ្ឍន៍សម្រាប់ការលក់នេះ (សូមមើលស.គ.អ.ក២ *សន្និធិ*) ឧទាហរណ៍

ដូចជាទ្រព្យដែលត្រូវទិញក្នុងគោលបំណងតែសម្រាប់លក់

បញ្ចេញចោល នាពេលខ្លីខាងមុខ ឬសម្រាប់កែច្នៃ និងលក់ចេញវិញ។

(ខ) ទ្រព្យដែលកំពុងត្រូវបានសាងសង់ ឬអភិវឌ្ឍនិក្ខុងនាមភាគីទី៣ (សូមមើល ស.គ.អ.ក ១១ *កិច្ចសន្យាសាងសង់*)។

(គ) ទ្រព្យកាន់កាប់ដោយម្ចាស់ (សូមមើល ស.គ.អ.ក ១៦) (ក្នុងចំណោមធាតុផ្សេងទៀត)រួមបញ្ចូល÷

ទ្រព្យដែលរក្សាទុកសម្រាប់ប្រើប្រាស់ នាពេលអនាគត ជាទ្រព្យកាន់កាប់ដោយម្ចាស់ទ្រព្យ ដែលរក្សាទុកសម្រាប់ការ អភិវឌ្ឍន៍ទៅអនាគត និងសម្រាប់ការប្រើប្រាស់ទៅថ្ងៃក្រោយ ធ្វើជាទ្រព្យដែលកាន់កាប់ដោយម្ចាស់ទ្រព្យដែលកាន់កាប់ដោយបុគ្គលិក (ទោះបីជាបុគ្គលិកទាំងនោះត្រូវបង់ឬមិនបង់ថ្លៃជួលទៅតាមអត្រាទីផ្សារក៏ដោយ) និងទ្រព្យដែលកាន់កាប់ដោយម្ចាស់ ដែលរង់ចាំការបោះចោល។

(ឃ) [លុបចោល]

(ង) ទ្រព្យដែលបានជួលទៅឱ្យអង្គភាពមួយផ្សេងទៀតក្រោមភតិសន្យាហិរញ្ញវត្ថុ ។

១០ ទ្រព្យខ្លះ មាននូវចំណែកដែលត្រូវរក្សាទុក ដើម្បីទទួលបាននូវថ្លៃជួល ឬដើម្បីបង្កើនតម្លៃមូលធនហើយមួយចំណែកទៀតរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬផ្គត់ផ្គង់ទំនិញ ឬសេវា ឬដើម្បីគោល បំណងរដ្ឋបាល។ ប្រសិនបើចំណែកទាំងនេះ អាចត្រូវបានលក់ដាច់ដោយឡែកៗ ពីគ្នានោះ (ឬត្រូវបានជួល ទៅឱ្យគេដោយឡែកៗពីគ្នា ក្រោមភតិសន្យាហិរញ្ញវត្ថុ)

អង្គភាព ត្រូវអនុវត្តគណនេយ្យកម្មដោយឡែកៗពីគ្នា។ ប្រសិនចំណែកទាំងនេះ មិនអាចត្រូវបានលក់ដាច់ពីគ្នាទេទ្រព្យទាំងនោះ គឺត្រូវចាត់ជាទ្រព្យវិនិយោគតែបើសិនចំណែកស្តួចស្តើងពេកគឺត្រូវចាត់ជាការរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬផ្គត់ផ្គង់ទំនិញឬសេវា ឬសម្រាប់គោលបំណងរដ្ឋបាល។

១១ ក្នុងករណីខ្លះ អង្គភាពមួយ ផ្តល់នូវសេវាកម្មបន្ទាប់បន្សំបន្ថែមទៀត ទៅឱ្យអ្នកគ្រប់គ្រងទ្រព្យ ដែលជាកម្មសិទ្ធិរបស់អង្គភាពនេះ។ អង្គភាពនោះត្រូវចាត់ទុកទ្រព្យនោះជាទ្រព្យវិនិយោគ បើសិនជាសេវាកម្មទាំងនោះ មិនមានសារៈសំខាន់ចំពោះការចាត់ចែងទាំងមូល ។ ឧទាហរណ៍ ដូចជានៅពេលដែលម្ចាស់អគារការិយាល័យបានផ្តល់នូវសេវាសន្តិសុខនិងការថែទាំទៅឱ្យភតិកៈដែលកាន់កាប់អាគារនោះ។

១២ ក្នុងករណីផ្សេងទៀត សេវាដែលបានផ្តល់មានសារៈសំខាន់។ ឧទាហរណ៍ បើសិនជាអង្គភាពមានសិទ្ធិ ចាត់ចែងសណ្ឋាគារមួយ សេវាដែលផ្តល់ឱ្យភ្ញៀវមានសារៈសំខាន់ចំពោះការចាត់ចែងទាំងមូល ។ ដូច្នេះ សណ្ឋាគារដែលចាត់ចែងដោយម្ចាស់ គឺជាទ្រព្យកាន់កាប់ដោយម្ចាស់ ហេតុនេះមិនអាចចាត់ជាទ្រព្យ វិនិយោគឡើយ។

១៣ វាអាចមានការពិបាកដើម្បីកំណត់ថាសេវាកម្មបន្ថែមមានសារៈសំខាន់ខ្លាំងដែលទ្រព្យសម្បត្តិមិនចាត់ទុកជាទ្រព្យវិនិយោគ។ ពេលខ្លះ ម្ចាស់សណ្ឋាគារផ្ទេរការទទួលខុសត្រូវមួយចំនួនទៅឱ្យភាគីទី៣(តតិយជន)ក្រោមកិច្ចសន្យាគ្រប់គ្រង។ លក្ខខណ្ឌនៃកិច្ចសន្យាប្រភេទនេះ មានភាពទូលំទូលាយខ្លាំង។ គំនិតម្ខាងយល់ឃើញថា ស្ថានភាពរបស់ម្ចាស់ជាក់ស្តែងអាចស្ថិតក្នុង

ស្ថានភាពជាអ្នកវិនិយោគអកម្ម ។ រីឯគំនិតម្ខាងទៀតយល់ឃើញថាម្ចាស់អាចគ្រាន់តែធ្វើកិច្ចសន្យាជួលអ្នកខាងក្រៅឱ្យមកធ្វើការប្រចាំថ្ងៃប៉ុន្តែកិច្ចការសំខាន់ៗខ្លួននៅតែបន្តការកាន់កាប់ដដែលដូចជា ការប្រែប្រួលនៃលំហូរសាច់ប្រាក់ដែលផលិត ឡើងដោយប្រតិបត្តិការអាជីវកម្ម របស់សណ្ឋាគារ។

១៤ ការវិនិច្ឆ័យត្រូវការជាចាំបាច់សម្រាប់កំណត់ថា តើទ្រព្យណាមួយចាត់ជាទ្រព្យវិនិយោគ។អង្គភាពត្រូវបង្កើតលក្ខណៈវិនិច្ឆ័យធ្វើដូច្នេះអង្គភាពអាចប្រើប្រាស់នូវការវិនិច្ឆ័យនោះឱ្យមានសង្គតិភាពដោយអនុលោមតាមនិយមន័យនៃទ្រព្យវិនិយោគនិងជាមួយ នឹងការណែនាំដែលទាក់ទិននៅក្នុងកថា-ខណ្ឌ ៧-១៣ ។ កថាខណ្ឌ ៧៥(គ) ទាមទារឱ្យអង្គភាពដាក់បង្ហាញព័ត៌មានអំពីលក្ខណៈវិនិច្ឆ័យទាំងនេះនៅពេលដែលការចាត់ថ្នាក់មានលក្ខណៈពិបាក ។

១៥ នៅក្នុងករណីខ្លះអង្គភាពមួយគ្រប់គ្រងទ្រព្យ ដែលបានជួលទ្រព្យនោះទៅឱ្យនិង កាន់កាប់ដោយក្រុមហ៊ុនមេរបស់ខ្លួនឬក្រុមហ៊ុនបុត្រសម្ព័ន្ធ មួយផ្សេងទៀត ។ ទ្រព្យនោះមិនបានបំពេញលក្ខណៈជាទ្រព្យវិនិយោគនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមឡើយ ពីព្រោះទ្រព្យនោះត្រូវបានកាន់កាប់ដោយម្ចាស់ ផ្អែកទៅតាមទស្សនៈវិស័យរបស់បណ្តុំក្រុមហ៊ុន។ ទោះបីជាយ៉ាងណាក៏ដោយ តាមទស្សនៈវិស័យរបស់អង្គភាព ដែលជាគ្រប់គ្រងទ្រព្យនោះទ្រព្យវិនិយោគនោះជាទ្រព្យវិនិយោគ បើសិនជាវាឆ្លើយតបទៅនឹងនិយមន័យដែលមានចែងនៅក្នុងកថាខណ្ឌ៥។ដូច្នេះភតិបតីចាត់ទុកទ្រព្យនេះជាទ្រព្យវិនិយោគនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ខ្លួន។

**១៦ ទ្រព្យវិនិយោគ នឹងត្រូវទទួលស្គាល់ថា ជាទ្រព្យសកម្មតែនៅពេល និងតែនៅពេលដែល ÷**

**(ក) ទំនងជាមាន ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលជាប់ទាក់ទិននឹងទ្រព្យវិនិយោគ នឹងហូរ ចូលទៅក្នុងអង្គភាព និង**

**(ខ) ថ្លៃដើមនៃទ្រព្យវិនិយោគ អាចត្រូវបានវាស់វែងដោយជឿជាក់បាន ។**

១៧ យោងតាមគោលការណ៍ទទួលស្គាល់នេះ អង្គភាពវាយតម្លៃថ្លៃដើមនៃទ្រព្យវិនិយោគទាំងអស់របស់ខ្លួននៅពេលគេទិញវា ។ ថ្លៃដើមទាំងនេះរួមមានថ្លៃចំណាយទិញទ្រព្យវិនិយោគនៅគ្រាដំបូងនិងថ្លៃចំណាយដែលកើតមានជាបន្តដែលបូកបន្ថែមឬជំនួសផ្នែកណាមួយឬផ្តល់សេវាថែទាំនៃទ្រព្យ ។

១៨ អនុលោមតាមគោលការណ៍ទទួលស្គាល់ ដែលចែងក្នុងកថាខណ្ឌ ១៦ អង្គភាពមិនទទួលស្គាល់ចំណាយថែទាំប្រចាំថ្ងៃទៅលើទ្រព្យនោះនៅក្នុងតម្លៃយោងនៃទ្រព្យវិនិយោគនោះទេ។ម្យ៉ាងវិញទៀត ការចំណាយទាំងនេះត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាត នៅពេលវាកើតមានតែម្តង។ ចំណាយនៃការថែទាំប្រចាំថ្ងៃគឺជាថ្លៃចំណាយទៅលើកម្លាំងពលកម្ម និងគ្រឿងប្រើប្រាស់ហើយអាចបញ្ចូលនូវថ្លៃចំណាយនៃផ្នែកតូចៗ ។ គោលបំណងនៃការចំណាយទាំងនេះជារឿយៗត្រូវបានចាត់ជា“ចំណាយការជួសជុល និង ការថែទាំ” នៃទ្រព្យនោះ។

១៩ ផ្នែកទាំងឡាយនៃទ្រព្យវិនិយោគ អាចត្រូវបានទិញតាមរបៀបការជំនួស។ ឧទាហរណ៍÷

ជញ្ជាំងខាងក្នុងអាចជាការជំនួសជញ្ជាំងដើម។យោងទៅតាមគោលការណ៍ទទួលស្គាល់ អង្គភាពត្រូវទទួលស្គាល់នៅក្នុងតម្លៃយោង នៃទ្រព្យវិនិយោគនូវថ្លៃដើមនៃការជំនួសផ្នែកណាមួយ នៃទ្រព្យវិនិយោគដែលមានស្រាប់នៅពេលដែលចំណាយនោះបានកើតឡើង ប្រសិនបើវាគោរពទៅតាមលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ ។ តម្លៃយោងនៃផ្នែកដែលត្រូវជំនួសទាំងនោះ ត្រូវបានឈប់ទទួលស្គាល់វិញស្របតាមបទបញ្ញត្តិឈប់ទទួលស្គាល់នៃស្តង់ដានេះ ។

## ការវាស់វែងនៅពេលការទទួលស្គាល់

**២០ ទ្រព្យវិនិយោគ ត្រូវបានវាស់វែងនៅគ្រាដំបូងតាមថ្លៃដើមរបស់វា។ ថ្លៃដើមប្រតិបត្តិការទាំងអស់ត្រូវបញ្ចូល ទៅក្នុងការវាស់វែងនៅគ្រាដំបូងនេះ ។**

២១ ថ្លៃដើមនៃទ្រព្យវិនិយោគដែលបានទិញរួមមានថ្លៃទិញ និងចំណាយដោយផ្ទាល់មួយចំនួន ។ ការចំណាយ ដោយផ្ទាល់មួយចំនួនរួមមានថ្លៃឈ្នួលវិជ្ជាជីវៈ សេវាច្បាប់ពន្ធលើការផ្ទេរទ្រព្យ និងចំណាយប្រតិបត្តិការផ្សេងៗទៀត។

២២ [លុបចោល

២៣ ថ្លៃដើមនៃទ្រព្យវិនិយោគ មិនត្រូវបានបង្កើនឡើងបានតាមរយៈ

(ក) ថ្លៃដើមចាប់ផ្តើមដំបូង (លុះត្រាតែវាចាំបាច់ ដើម្បីនាំទ្រព្យនោះមកកាន់លក្ខខណ្ឌដែលចាំបាច់ដើម្បីឱ្យទ្រព្យនោះ អាចដំណើរការទៅតាមការចង់បានរបស់គណៈគ្រប់គ្រង)

(ខ) ការខាតបង់ក្នុងប្រតិបត្តិការដែលបានកើតមានមុនពេលទ្រព្យវិនិយោគសម្រេចបាននូវកម្រិតនៃការកាន់កាប់ទៅតាមការគ្រោងទុក ឬ

(គ) ចំនួនទឹកប្រាក់មិនប្រក្រតីលើភាពខ្ជះខ្ជាយនៃការប្រើប្រាស់សម្ភារៈកម្លាំងពលកម្មនិងធនធានផ្សេងទៀតដែលកើតមាននៅក្នុងពេលសាងសង់ និងអភិវឌ្ឍន៍ទ្រព្យនោះ។

២៤ ប្រសិនបើការទូទាត់សម្រាប់ទ្រព្យវិនិយោគ ត្រូវបានពន្យាពេល នោះថ្លៃដើម របស់វាគឺជាតំលៃសមមូលជាសាច់ប្រាក់ ។ ភាពខុសគ្នារវាងទឹកប្រាក់នេះ និងទឹកប្រាក់ទូទាត់សរុបត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់លើពេលនៃការជំពាក់។

**២៥ ថ្លៃដើមដំបូងនៃភាគកម្មទ្រព្យ រក្សាទុកក្រោមភតិសន្យាមួយ និងដែលបានចាត់ជាទ្រព្យវិនិយោគត្រូវកំណត់ថាជាភតិសន្យាហិរញ្ញវត្ថុតាមរយៈកថាខណ្ឌ ២០នៃ ស.គ.អ.ក ១៧ ពោលគឺ ទ្រព្យសកម្មនោះ ត្រូវបានទទួលស្គាល់ជាតម្លៃទាបជាងគេ នៃតម្លៃសមស្របនៃទ្រព្យ និងតម្លៃបច្ចុប្បន្ននៃថ្លៃឈ្នួលអប្បបរមាភតិសន្យា ។ ចំនួនទឹកប្រាក់សមមូលត្រូវបានទទួលស្គាល់ជាបំណុល ដោយយោងទៅតាមកថាខណ្ឌដដែលនេះ ។**

២៦ ទឹកប្រាក់បន្ថែមដែលបានបង់សម្រាប់ភតិសន្យាត្រូវបានចាត់ទុកថាជាផ្នែកមួយថ្លៃឈ្នួលអប្បបរមានៃភតិសន្យា (សម្រាប់គោលបំណងនេះ) ត្រូវបានបញ្ចូលទៅក្នុងថ្លៃដើមនៃទ្រព្យសកម្ម ប៉ុន្តែត្រូវដកចេញពីបំណុលវិញ ។ ប្រសិនបើភាគកម្មទ្រព្យដែលត្រូវរក្សាទុកក្រោមភតិសន្យា ត្រូវបានចាត់ជា

ទ្រព្យវិនិយោគ ទ្រព្យដែលបានកត់ត្រាក្នុងគណនេយ្យតាមតម្លៃសមស្រប វាគឺជាភាគកម្មវាមិនមែនជាទ្រព្យមូលដ្ឋានទេ។ការណែនាំអំពីការកំណត់តម្លៃសមស្របនៃភាគកម្មរបស់ទ្រព្យនោះ ត្រូវបានកំណត់តាមវិធីសាស្ត្រតម្លៃសមស្របដែលមានចែងក្នុងកថាខណ្ឌ ៣៣-៥២ ។ ការណែនាំនោះក៏ជាប់ពាក់ព័ន្ធទៅនឹងការកំណត់តម្លៃសមស្របនៅពេលដែលតម្លៃនោះត្រូវបានប្រើជាថ្លៃដើមសម្រាប់គោលបំណងនៃការទទួលស្គាល់នាគ្រាដំបូង។

២៧ ទ្រព្យវិនិយោគមួយ ឬច្រើនអាចត្រូវបានទិញដោយការដោះដូរទៅនឹងទ្រព្យសកម្ម ដែលមិនមែនជារូបិយវត្ថុ ឬទ្រព្យសកម្ម ឬការផ្សំចូលគ្នានៃទ្រព្យសកម្មដែលជារូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។ ការពិភាក្សាខាងក្រោមសំដៅទៅដល់ការដោះដូរទ្រព្យសកម្មមិនមែនរូបិយវត្ថុយកទ្រព្យសកម្មមួយផ្សេងទៀត ប៉ុន្តែវាក៏អនុវត្តចំពោះការដោះដូរទាំងឡាយ ដែលមានបរិយាយនៅក្នុងប្រយោគពីមុនមកផងដែរ ។ ថ្លៃដើមនៃទ្រព្យវិនិយោគប្រភេទ នេះត្រូវបានវាស់វែងទៅតាមតម្លៃសមស្របលើកលែងតែ (ក) ប្រតិបត្តិការនៃការដោះដូរនោះខ្វះនូវភាពសំខាន់ពាណិជ្ជកម្មឬ (ខ) តម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវទទួលនិងទ្រព្យសកម្មដែលត្រូវបោះចោល ដែលមិនអាចវាស់វែងបានដោយភាពជឿជាក់។ ទ្រព្យសកម្មដែលបានទិញ ត្រូវបានវាស់វែងតាមមធ្យោបាយនេះទោះបីជា អង្គភាពឈប់ទទួលស្គាល់ទ្រព្យសកម្មនោះវិញ ដោយសារការបោះចោលក៏ដោយ ។ ប្រសិនបើទ្រព្យសកម្មដែលបានទិញនោះ មិនអាចវាស់វែងបាន តាមតម្លៃសមស្របនោះទេ ក៏ថ្លៃដើមរបស់វាត្រូវវាស់វែងទៅតាមតម្លៃយោងនៃទ្រព្យសកម្ម ដែលបានបោះចោលនោះដែរ ។

២៨ អង្គភាពត្រូវកំណត់ថាតើប្រតិបត្តិការដោះដូរមានភាពសំខាន់ខាងពាណិជ្ជ-កម្មដែរ ឬអត់ ដោយពិចារណាអំពីវិសាលភាពនៃទំហំលំហូរសាច់ប្រាក់នាពេលអនាគតរបស់វាដែលត្រូវបានរំពឹងថានឹងមានការផ្លាស់ប្តូរជាលទ្ធ-ផលនៃប្រតិបត្តិការនោះ ។ ប្រតិបត្តិការនៃការដោះដូរ មានភាពសំខាន់ពាណិជ្ជកម្ម ប្រសិបើ ÷

(ក) រូបសណ្ឋាន (ហានិភ័យពេលវេលា និងទឹកប្រាក់) នៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម ដែលបានទទួលខុសពីរូបសណ្ឋាននៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មដែលបានផ្ទេរ ឬ

(ខ) តម្លៃជាក់លាក់មួយផ្នែកនៃបំណែកនៃកិច្ចប្រតិបត្តិការរបស់អង្គភាពដែលទទួលរងឥទ្ធិពលដោយសារផ្លាស់ប្តូរប្រតិបត្តិការជាលទ្ធផលនៃការដោះដូរនោះ និង

(គ) ភាពខុសគ្នានៅក្នុងចំណុច (ក) ឬ (ខ) វាមានទំនាក់ទំនងដ៏សំខាន់ទៅនឹងតម្លៃសមស្របនៃទ្រព្យ សកម្មដែលបានដោះដូរនោះ។

សម្រាប់គោលបំណងនៃការកំណត់ថា តើប្រតិបត្តិការដោះដូរមានលក្ខណៈពាណិជ្ជកម្មដែរឬអត់នោះ តម្លៃកំណត់ជាក់លាក់នៃចំណែកដំណើរការរបស់អង្គភាពដែលរងឥទ្ធិពលដោយប្រតិបត្តិការនោះ នឹងឆ្លុះបញ្ចាំងពីលំហូរសាច់ប្រាក់ក្រោយពេលបង់ពន្ធ ។ លទ្ធផលនៃការវិភាគទាំងនេះ អាចមានលក្ខណៈច្បាស់លាស់ដោយមិនតម្រូវឱ្យអង្គភាពធ្វើការគណនាលម្អិតនោះឡើយ ។

២៩ តម្លៃសមស្របនៃទ្រព្យសកម្មដែលប្រតិបត្តិការទីផ្សារអាចប្រៀបធៀបបានមិនកើតមាន គឺជាវាស់វែងបានដោយភាពជឿជាក់ទេប្រសិនបើ (ក)

បម្រែបម្រួលនៅក្នុងចន្លោះនៃប៉ាន់ស្មានតម្លៃសមស្របមិនសំខាន់សម្រាប់ទ្រព្យសកម្មនោះ ឬ(ខ) ភវនីយភាពនៃការប៉ាន់ស្មាននានា នៅក្នុងចន្លោះនោះ អាចត្រូវបានវាយតម្លៃសមហេតុផល និងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ស្មានពីសមស្រប។ ប្រសិនបើអង្គភាពនោះ អាចកំណត់ដោយជឿជាក់នូវតម្លៃសមស្រប នៃទ្រព្យសកម្មដែលបានទទួល ឬទ្រព្យសកម្មដែលបានបោះបង់ចោល ពេលនោះតម្លៃសមស្របរបស់ទ្រព្យសកម្មដែលត្រូវបោះ-ចោល ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងនូវថ្លៃដើម លើកលែងតែតម្លៃសម-ស្របនៃទ្រព្យសកម្មដែលទទួលមានភាពច្បាស់លាស់ជាងនេះ។

## ការវាស់វែងក្រោយពេលទទួលស្គាល់

### គោលនយោបាយគណនេយ្យ

៣០ **ដោយមានករណីលើកលែងមួយចំនួន ដូចបានចែងនៅក្នុង កថាខណ្ឌ ៣២ក និង៣៤ អង្គភាពត្រូវជ្រើសរើស ដើម្បីយកទៅធ្វើជាគោលនយោបាយគណនេយ្យរបស់ខ្លួន នូវវិធីសាស្ត្រតម្លៃសមស្រប នៅក្នុងកថាខណ្ឌ ៣៣-៣៥ ឬ វិធីសាស្ត្រថ្លៃដើមនៅក្នុងកថាខណ្ឌ ៥៦ ហើយត្រូវអនុវត្តគោលនយោបាយនោះ ចំពោះទ្រព្យវិនិយោគទាំងអស់របស់ខ្លួន។**

៣១ ស.គ.អ.ក ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង*ចែងថាការផ្លាស់ប្តូរគោលនយោបាយគណ-នេយ្យ នឹងត្រូវបានធ្វើឡើងតែក្នុងករណីការផ្លាស់ប្តូរនោះនឹងស្តែងឡើងតាមការបង្ហាញយ៉ាងត្រឹមត្រូវ អំពីបណ្តាប្រតិបត្តិការព្រឹត្តិការណ៍ ឬ

ស្ថានភាពដ៏ទៃទៀត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ។ វាមិនទំនងទេដែលថា ការផ្លាស់ប្តូរពីវិធីសាស្ត្រតម្លៃសមស្របទៅជាវិធីសាស្ត្រថ្លៃដើមនឹងធ្វើឱ្យមានការបង្ហាញដ៏ត្រឹមត្រូវជាងមុននោះ។

៣២ ស្តង់ដានេះតម្រូវឱ្យអង្គភាពទាំងអស់ធ្វើការកំណត់តម្លៃសមស្របនៃទ្រព្យវិនិយោគ ក្នុងគោលបំណងនៃការវាស់វែងផង (បើសិនអង្គភាពនោះប្រើប្រាស់វិធីសាស្ត្រតម្លៃសមស្រប) ឬការលាតត្រដាងព័ត៌មានផង(បើសិនវាប្រើប្រាស់វិធីសាស្ត្រថ្លៃដើម)។អង្គភាពមួយត្រូវបានលើកទឹកចិត្ត (ប៉ុន្តែមិនតម្រូវ ) ឱ្យកំណត់តម្លៃសមស្របនៃទ្រព្យវិនិយោគ ដោយឈរលើមូលដ្ឋាននៃការវាយតម្លៃដោយអ្នកវាយតម្លៃឯករាជ្យ ដែលមានគុណវុឌ្ឍិជំនាញពាក់ព័ន្ធ និងត្រូវបានគេទទួលស្គាល់ ហើយមានបទពិសោធន៍ថ្មីខាងទីតាំង និងប្រភេទនៃទ្រព្យវិនិយោគដែលកំពុងត្រូវបានវាយតម្លៃ។

**៣២ក. អង្គភាពអាច ÷**

**(ក) ជ្រើសរើសវិធីសាស្ត្រតម្លៃសមស្រប ឬវិធីសាស្ត្រថ្លៃដើមសម្រាប់ទ្រព្យវិនិយោគដែលប្រើសម្រាប់ គាំទ្រដល់បំណុលទាំងឡាយដែលផ្តល់នូវផលត្រឡប់វិញ ជាប់ទាក់ទងដោយផ្ទាល់ទៅនឹងតម្លៃទីផ្សារ ឬផលបានមកពីទ្រព្យសកម្មជាក់លាក់នោះរួមមានទ្រព្យវិនិយោគផងដែរ និង**

**(ខ) ជ្រើសរើសវិធីសាស្ត្រតម្លៃសមស្រប ឬ វិធីសាស្ត្រថ្លៃដើមសម្រាប់រាល់ទ្រព្យវិនិយោគដទៃទៀត ទាំងអស់ដោយមិនគិតពីជម្រើសដែល បានធ្វើឡើងនៅក្នុងចំណុច (ក) នោះទេ។**

៣២ខ. ក្រុមហ៊ុនផ្តល់ធានារ៉ាប់រងខ្លះ និងអង្គភាពដទៃដំណើរការមូលនិធិទ្រព្យផ្ទៃក្នុងដែលបោះចេញនូវឯកត្តាជាសញ្ញាណ ដោយឯកត្តាខ្លះត្រូវបានកាន់កាប់ ដោយពួកអ្នកវិនិយោគនៅក្នុងកិច្ចសន្យាដែលចងភ្ជាប់គ្នា និងឯកតាផ្សេងទៀត ត្រូវបានកាន់កាប់ដោយអង្គភាពនោះ។ កថាខណ្ឌ ៣២ក មិនអនុញ្ញាតឱ្យអង្គភាពមួយធ្វើការវាស់វែងទ្រព្យដែលគ្រប់គ្រងដោយមូលនិធិមួយផ្នែក ទៅតាមថ្លៃដើម និងមួយផ្នែក ទៅតាមតម្លៃសមស្របនោះទេ ។

៣២គ. បើសិនអង្គភាពមួយជ្រើសរើសវិធីសាស្ត្រប្លែកៗពីគ្នាសម្រាប់ប្រភេទទាំង២ ដូចបានរៀបរាប់នៅក្នុង កថាខណ្ឌ ៣២ក នោះការលក់ទ្រព្យវិនិយោគចន្លោះ រវាងក្រុមទ្រព្យសកម្ម ដែលត្រូវបានវាស់វែង ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា ត្រូវបានទទួលស្គាល់ទៅតាមតម្លៃសមស្រប ហើយបំរែបំរួលបន្តបន្ទាប់ នៃតម្លៃសមស្របត្រូវទទួលស្គាល់ថាជាចំណេញ ឬខាត។ អាស្រ័យហេតុនេះ បើសិនទ្រព្យវិនិយោគ ត្រូវបានគេលក់ចេញពីក្រុមណាមួយ ដែលគេប្រើវិធីសាស្ត្រតម្លៃសមស្រប នៅក្នុងក្រុមមួយទៀតដែលគេប្រើវិធីសាស្ត្រថ្លៃដើមដែរ តម្លៃសមស្របរបស់ទ្រព្យនោះនៅថ្ងៃដែលលក់ ត្រូវក្លាយទៅជាថ្លៃដើមជំនួសរបស់វា ។

## វិធីសាស្ត្រតម្លៃសមស្រប

**៣៣ ក្រោយពីការទទួលស្គាល់លើកដំបូង អង្គភាពដែលជ្រើសរើសវិធីសាស្ត្រតម្លៃសមស្របត្រូវវាស់វែងទ្រព្យវិនិយោគទាំងអស់របស់ខ្លួនទៅតាមតម្លៃសមស្រប លើកលែងតែ ក្នុងករណីដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥៣។**

៣៤ **នៅពេលដែលភាគកម្មនៃទ្រព្យ ដែលត្រូវរក្សាទុកដោយភតិកៈក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានចាត់ថ្នាក់ជាទ្រព្យវិនិយោគ ដោយអនុលោមតាមកថាខណ្ឌ ៦នោះ កថាខណ្ឌ ៣០ មិនត្រូវបានគេជ្រើសរើសទេ ពោលគឺវិធីសាស្ត្រតម្លៃសមស្របនឹងត្រូវបានអនុវត្ត។**

៣៥ **ចំណេញ ឬខាត ដែលកើតចេញពីបម្រែបម្រួលតាមតម្លៃសមស្របនៃទ្រព្យវិនិយោគ ត្រូវបានទទួលស្គាល់ ក្នុងប្រាក់ចំណេញ ឬខាត នៅក្នុងដែលវាកើតមាន។**

៣៦ តម្លៃសមស្របនៃទ្រព្យវិនិយោគគឺជាថ្លៃលក់ដែលទ្រព្យនោះអាចត្រូវបានដោះដូររវាងភាគីដែលមានឆន្ទៈ និងព័ត៌មានពេញលេញនៅក្នុងប្រតិបត្តិការស្រដៀងគ្នា (សូមមើលកថាខណ្ឌ ៥)។ ជាក់ស្តែងតម្លៃសមស្របមិនបូកបញ្ចូលនូវថ្លៃលក់ប៉ាន់ស្មានដែលរងនូវអតិផរណា ឬបរិត្តផរណាដោយ សារលក្ខខណ្ឌឬកាលៈទេសៈពិសេសៗដូចជាការចាត់ចែងហិរញ្ញវត្ថុការលក់និងជួលមកវិញ ការពិចារណាពិសេសឬសម្បទានពិសេស ដែលផ្តល់ដោយអ្នកជាប់ពាក់ព័ន្ធ នឹងការលក់នោះ ។

៣៧ អង្គភាពមួយត្រូវកំណត់តម្លៃសមស្របដោយមិនធ្វើការកាត់បន្ថយចំណាយប្រតិបត្តិការ ណាមួយដែលអាចកើតមាននៅពេលលក់ ឬពេលបញ្ចេញចោល ។

៣៨ **តម្លៃសមស្របនៃទ្រព្យវិនិយោគត្រូវឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារនៅចុងការិយបរិច្ឆេទរាយការណ៍។**

៣៩ តម្លៃសមស្របតំលៃនៅពេលវេលាមួយជាក់លាក់ត្រឹមកាលបរិច្ឆេទណាមួយ ។ ដោយសារលក្ខខណ្ឌទីផ្សារ អាចមានការប្រែប្រួល នោះទឹកប្រាក់

ដែលបានរាយការណ៍ជាតម្លៃសមស្របអាចខុស ឬមិនសមហេតុផល ប្រសិនបើ ត្រូវបានប៉ាន់ស្មាននៅពេលណាមួយផ្សេងទៀត ។ ការកំណត់នៃតម្លៃសមស្រប ក៏ត្រូវសន្មតពីការដោះដូរដែលកើតឡើង ដំណាលគ្នានឹងការបញ្ចប់កិច្ចសន្យាលក់ ដោយគ្មានបម្រែបម្រួលថ្លៃលក់ ដែលទំនងជាអាចធ្វើឡើងក្នុងប្រតិបត្តិធម្មតារវាងភាគីដែលមានឆន្ទៈនិងមានចំណេះដឹងប្រសិនបើការដោះដូរ និងការបញ្ចប់កិច្ចសន្យា មិនកើតឡើងដំណាលគ្នានោះទេ។

៤០ ក្រៅពីនេះ តម្លៃសមស្របនៃទ្រព្យវិនិយោគ ឆ្លុះបញ្ចាំងពីចំណូលនៃការជួលបានពីភតិសន្យាបច្ចុប្បន្ន និងការសន្មតដែលមានលក្ខណៈគាំទ្រ និងសមស្រប ដែលតំណាងឱ្យអ្វីដែលភាគីដែលមានឆន្ទៈ និងព័ត៌មាន ពេញលេញនឹងសន្មតអំពីចំណូលនៃការជួលនៃភតិសន្យានាពេលអនាគត ដោយពិចារណាអំពីលក្ខខណ្ឌបច្ចុប្បន្ន ។ ម្យ៉ាងវិញទៀត ដោយឈរលើមូលដ្ឋានប្រហាក់ប្រហែលគ្នា វាក៏ឆ្លុះបញ្ចាំង ពីលំហូរសាច់ប្រាក់ចេញ (ក្នុងនោះមានការបង់ថ្លៃជួលនិងលំហូរសាច់ប្រាក់ចេញដទៃទៀត) ដែលអាចត្រូវបានរំពឹងទុកពីទ្រព្យនោះ ។ លំហូរសាច់ប្រាក់ចេញខ្លះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបំណុល រីឯខ្លះទៀត ជាប់ទាក់ទងទៅនឹងលំហូរសាច់ប្រាក់ចេញ ដែលមិនត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរហូតដល់កាលបរិច្ឆេទក្រោយទៀត (ឧទាហរណ៍÷ ការទូទាត់តាមកាលកំណត់ ដូចជាការជួលជាយថាហេតុ)។

៤០ កថាខណ្ឌ ២៥ បញ្ជាក់ពីមូលដ្ឋានក្នុងការទទួលស្គាល់ជាដំបូងនូវថ្លៃដើមនៃភាគកម្មទ្រព្យភតិនសន្យា ។ កថាខណ្ឌ ៣៣ ទាមទារឱ្យមានការវាស់

វែងភាគកម្មនៃទ្រព្យឡើងវិញទៅតាមតម្លៃទីផ្សារប្រសិនបើជាចាំបាច់ ។ នៅក្នុងភតិសន្យាដែលចរចាទៅតាមអត្រាទីផ្សារ ពោលគឺ តម្លៃសមស្រប របស់ភាគកម្មនៃទ្រព្យនៅពេលទិញ ដកចេញថ្លៃឈ្នួលនៃភតិសន្យា ទាំង អស់ដែលរំពឹងទុក (រួមមានថ្លៃទូទាត់ដែលទាក់ទងនឹងបំណុលបានទទួល ស្គាល់) គួរតែស្មើនឹងសូន្យ។ តម្លៃសមស្របនេះ មិនប្រែប្រួលទេ ដោយ មិនគិតថា សម្រាប់គោលបំណងគណនេយ្យ តើទ្រព្យសកម្មដែលត្រូវ បានជួល និងបំណុលត្រូវបាន ទទួលស្គាល់ទៅតាមតម្លៃសមស្រប ឬ តម្លៃបច្ចុប្បន្ននៃថ្លៃឈ្នួលអប្បបរមាក្នុងភតិសន្យាដែរឬអត់ ដោយយោង ទៅតាមកថាខណ្ឌ ២០ នៃ ស.គ.អ.ក ១៧ ។ ដូចនេះ ការវាស់វែង ឡើងវិញនូវទ្រព្យសកម្មដែលបានជួលពីថ្លៃដើមដែលស្របតាមកថាខណ្ឌ ២៥ ទៅតម្លៃសមស្របដែលស្របតាមកថាខណ្ឌ ៣៣ មិនគួរឱ្យកើត មានចំណេញ ឬខាត នៅគ្រាដំបូងឡើយ លើកលែងតែ តម្លៃសមស្រប ត្រូវបានវាស់វែងនៅពេលផ្សេងពីនេះ ។ ករណីនេះ អាចកើតមាននៅ ពេលដែលការជ្រើសរើសអនុវត្តវិធីសាស្ត្រតម្លៃទីផ្សារត្រូវបានគេធ្វើឡើង នៅបន្ទាប់ពីការទទួលស្គាល់នាគ្រាដំបូង ។

៤២ និយមន័យនៃតម្លៃសមស្របសំដៅទៅដល់ភាគីដែលមានឆន្ទៈនិងព័ត៌- មាន ពេញលេញ។ នៅក្នុងបរិការណ៍នេះពាក្យថា “មានព័ត៌មានពេញ លេញមានន័យថាទាំងអ្នកទិញ និងអ្នកលក់សុទ្ធតែមានឆន្ទៈ និងត្រូវបាន ផ្តល់ព័ត៌មានយ៉ាងសមស្របអំពីប្រភេទនិងលក្ខណៈនៃទ្រព្យវិនិយោគការ ប្រើប្រាស់ជាក់ស្តែងនិងសក្តានុពលរបស់វាព្រមទាំងលក្ខខណ្ឌទីផ្សារនៅ កាលបរិច្ឆេទរាយការណ៍។ អ្នកទិញដែលមានឆន្ទៈ ត្រូវបានជំរុញឱ្យទិញ

មិនមែនបង្ខំឱ្យទិញនោះទេ។ អ្នកទិញនេះគ្មានចំណង់ខ្លាំង និងកំណត់ឱ្យទិញ តាមតម្លៃណាមួយនោះឡើយ ។ អ្នកទិញដែលត្រូវគេបានសន្មតថា នឹងមិនចំណាយក្នុងតម្លៃណាមួយ ខ្ពស់ជាងទីផ្សារដែលមានអ្នកលក់ អ្នកទិញ និងអ្នកលក់ដែលមានឆន្ទៈ និងព័ត៌មានពេញលេញនោះទេ។

៤៣ អ្នកលក់ដោយឆន្ទៈ មិនមែនជាអ្នកលក់ដែលមានចំណង់ខ្លាំង និងត្រូវបានគេបង្ខំឱ្យលក់ត្រង់តម្លៃណាមួយ ដែលមិនសមស្របនឹងតម្លៃសមស្របបច្ចុប្បន្ននោះទេ ។ អ្នកលក់ដែលមានឆន្ទៈ ត្រូវបានលើកទឹកចិត្តឱ្យលក់ទ្រព្យវិនិយោគទៅតាមលក្ខខណ្ឌទីផ្សារ ទៅតាមតម្លៃសមស្របមួយដែលអាចទទួលយកបាន ។ ស្ថានភាពពិតនៃម្ចាស់ទ្រព្យវិនិយោគជាក់ស្តែង មិនមែនជាផ្នែកមួយនៃតម្លៃដោះដូរនោះទេដោយសារតែអ្នកលក់ដែលមានឆន្ទៈនោះ គឺជាម្ចាស់តាមសម្មតិកម្ម (ឧទាហរណ៍អ្នកលក់ដែលមានឆន្ទៈ នឹងមិន ពិចារណាបកស្រាយពីស្ថានភាពពន្ធអាករពិសេសរបស់ម្ចាស់ទ្រព្យវិនិយោគជាក់ស្តែងនោះទេ )។

៤៤ និយមន័យនៃតម្លៃសមស្របសំដៅទៅដល់ប្រតិបត្តិការបើកចំហ ។ ប្រតិបត្តិការបើកចំហគឺជាប្រតិបត្តិការមួយរវាងភាគីនានាដែលគ្មានទំនាក់ទំនងពិសេសដែលធ្វើឱ្យថ្លៃលក់នៃប្រតិបត្តិការខុសពីស្ថានភាពទីផ្សារធម្មតា ។ ប្រតិបត្តិការនេះ ត្រូវបានសន្មតថា កើតមានរវាងភាគីដែលគ្មានទំនាក់ទំនងគ្នាពោលគឺភាគីនីមួយៗធ្វើការដោយឯករាជ្យពីគ្នា ។

៤៥ ភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្រប ត្រូវបានផ្តល់តាមរយៈថ្លៃលក់បច្ចុប្បន្ននៅក្នុងទីផ្សារសកម្មមួយ សម្រាប់ទ្រព្យប្រហាក់ប្រហែលគ្នា នៅក្នុងទីតាំងនិងស្ថានភាពដូចគ្នា ហើយប្រែប្រួលទៅតាមកិច្ចសន្យាភតិសន្យាប្រហាក់

ប្រហែល និងកិច្ចសន្យាផ្សេងទៀត។ អង្គភាពត្រូវយកចិត្តទុកក្នុងការកំណត់ ភាពខុសគ្នា នៃប្រភេទទីតាំង ឬលក្ខខណ្ឌនៃទ្រព្យនោះ ឬក្នុងលក្ខខណ្ឌកិច្ចសន្យាភតិសន្យា និងកិច្ចសន្យាដទៃទៀត ដែលទាក់ទិនទៅនឹងទ្រព្យនោះ។

៤៦ ក្នុងករណីដែលគ្មានតម្លៃបច្ចុប្បន្ននៅក្នុងទីផ្សារសកម្មមួយនៃប្រភេទទំនិញដែលបានពណ៌នានៅក្នុងកថាខណ្ឌ៤៥ អង្គភាព ត្រូវធ្វើការពិចារណាព័ត៌មានដែលបានទទួលពីផ្នែកផ្សេងៗគ្នា រួមមាន ÷

(ក) ថ្លៃបច្ចុប្បន្ននៅក្នុងទីផ្សារសកម្មនៃទ្រព្យដទៃទៀត ដែលមានប្រភេទផ្សេងគ្នា ស្ថានភាព ឬទីតាំង (យោងតាមភាពខុសគ្នានៃការជួល ឬកិច្ចសន្យាដទៃទៀត) ដោយធ្វើនិយ័តកម្មឱ្យសមស្របឆ្លុះបញ្ចាំងឱ្យឃើញនូវភាពខុសគ្នាទាំងនោះ។

(ខ) តម្លៃថ្មីៗនៃទ្រព្យប្រហាក់ប្រហែលគ្នា នៅក្នុងទីផ្សារមិនសូវសកម្ម ដោយធ្វើនិយ័តកម្ម ដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលលក្ខខណ្ឌសេដ្ឋកិច្ច តាំងពីពេលដែលប្រតិបត្តិការនោះកើតឡើង ចំពោះតម្លៃទាំងនោះ និង

(គ) អប្បហារលំហូរសាច់ប្រាក់ផ្អែកលើការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគត គាំទ្រដោយលក្ខខណ្ឌ នៃការជួលដែលមានស្រាប់ និងកិច្ចសន្យាផ្សេងៗទៀត និង(ពេលដែលអាច) ដោយភស្តុតាង ខាងក្រៅដូចជា ថ្លៃជួលទីផ្សារបច្ចុប្បន្នសម្រាប់ទ្រព្យស្រដៀងគ្នា នៅក្នុងទីតាំងនិងលក្ខខណ្ឌដូចគ្នានិងប្រើប្រាស់អត្រាអប្បហារដែលឆ្លុះបញ្ចាំងក្នុងការវាយតម្លៃសមស្របបច្ចុប្បន្ន

អំពីភាពមិនប្រាកដនៃបរិមាណនិងពេលវេលានៃលំហូរ
សាច់ប្រាក់ ។

៤៧ ក្នុងករណីខ្លះទៀត ប្រភពផ្សេងៗគ្នាដែលមាននៅក្នុងកថាខណ្ឌមុនអាចបង្ហាញនូវសេចក្តីសន្និដ្ឋានផ្សេងៗទៀតអំពីតម្លៃសមស្របនៃទ្រព្យវិនិយោគ ។ អង្គភាពមួយ ពិចារណាអំពីហេតុផលនៃភាពខុសគ្នាទាំងនោះដើម្បីឱ្យឈានដល់ការប៉ាន់ស្មាននៃតម្លៃសមស្របដែលអាចយកជាការបានក្នុងចន្លោះនៃតម្លៃប៉ាន់ស្មានសមស្រប ។

៤៨ ករណីពិសេសខ្លះទៀត មានភស្តុតាងច្បាស់លាស់នៅពេលដែលអង្គភាពមួយ ទិញទ្រព្យវិនិយោគដំបូង (ឬនៅពេលដែលទ្រព្យដែលមានស្រាប់បានក្លាយទៅជាទ្រព្យវិនិយោគ បន្ទាប់ពីមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់) ដែលបង្ហាញថាភាពផ្លាស់ប្តូរនៃចន្លោះ ប៉ាន់ស្មានតម្លៃសមស្របសមស្របមានកម្រិតខ្ពស់ ហើយការវាយតម្លៃនៃលទ្ធផលមានការលំបាករហូតដល់សារៈប្រយោជន៍នៃតម្លៃសមស្របប៉ាន់ស្មានតែមួយ អាចត្រូវបានបោះបង់ចោល ។ នោះបញ្ជាក់ថា តម្លៃសមស្របនៃទ្រព្យមិនអាចកំណត់បានត្រឹមត្រូវលើមូលដ្ឋានបន្តបន្ទាប់នោះទេ (សូមមើលកថាខណ្ឌ ៥៣)។

៤៩ តម្លៃសមស្របខុសពីតម្លៃប្រើប្រាស់ ដូចបានកំណត់នៅក្នុង ស.គ.អ ៣៦ *ការធ្លាក់តំលៃនៃទ្រព្យសកម្ម* ។ តម្លៃសមស្របឆ្លុះបញ្ចាំងអំពីចំណេះដឹងខាងការប៉ាន់ស្មានរបស់អ្នកលក់ និងអ្នកទិញ ដែលមានការយល់ដឹង និងមានឆន្ទៈ ។ ផ្ទុយទៅវិញ តម្លៃប្រើប្រាស់ឆ្លុះបញ្ចាំងអំពីការ ប៉ាន់ស្មានរបស់អង្គភាព រួមទាំងផលប៉ះពាល់នៃកត្តាជាក់លាក់ណាមួយ ចំពោះអង្គភាពនិងមិនអាចអនុវត្តចំពោះអង្គភាពជាលក្ខណៈទូទៅបានទេ ។

ឧទាហរណ៍តម្លៃសមស្របទីផ្សារមិនឆ្លុះបញ្ចាំងអំពីកត្តាខាងក្រោមដែលអ្នកទិញ និងអ្នកលក់ជាទូទៅមិនអាចរកបាន ÷

(ក) តម្លៃបន្ថែម ដែលបានមកពីការបង្កើតបណ្តុំទ្រព្យ នៅទីកន្លែងខុសគ្នា

(ខ) ថាមពលរួមគ្នារវាងទ្រព្យវិនិយោគ និងទ្រព្យសកម្មផ្សេងទៀត

(គ) សិទ្ធិស្របច្បាប់ ឬការកំណត់របស់ច្បាប់ ដែលកំណត់ចំពោះម្ចាស់បច្ចុប្បន្ន និង

(ឃ) ផលចំណេញពន្ធ ឬបន្ទុកពន្ធដែលកំណត់ចំពោះម្ចាស់បច្ចុប្បន្ន

៥០ ក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យវិនិយោគតាមវិធីសាស្ត្រសមស្របអង្គភាពមួយមិនត្រូវរាប់ទ្វេរដងនៃទ្រព្យសកម្ម ឬបំណុល ដែលបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក ឬបំណុលឡើយ ។ ឧទាហរណ៍ ÷

(ក) ឧបករណ៍ ដូចជាជណ្តើរយន្ត ឬម៉ាស៊ីនត្រជាក់ ត្រូវបានបញ្ចូលជាផ្នែកមួយនៃអាគារ និងជាធម្មតា ត្រូវបានបញ្ចូលជានៅក្នុងតម្លៃសមស្របនៃទ្រព្យវិនិយោគ ជាជាងទទួលស្គាល់ដាច់ដោយឡែកជាទ្រព្យ រោងចក្រ និងឧបករណ៍

(ខ) ប្រសិនបើការិយាល័យមួយត្រូវបានជួលក្នុងលក្ខណៈ ជាគ្រឿង-សង្ហារឹម តម្លៃនៃទីផ្សារសម្រាប់ការិយាល័យនោះ ជាទូទៅរួមបញ្ចូលទាំងតម្លៃសមស្របនៃគ្រឿងសង្ហារឹមនោះពីព្រោះ ការជួលមានការជាប់ពាក់ព័ន្ធទៅនឹងការិយាល័យគ្រឿងសង្ហារឹមនោះ ។ នៅពេលដែលគ្រឿង សង្ហារឹម ត្រូវបញ្ចូលទៅក្នុង តម្លៃសមស្រប

នៃទ្រព្យវិនិយោគ អង្គភាពមួយ មិនត្រូវបានទទួលស្គាល់គ្រឿងសង្ហារឹម ជាទ្រព្យសកម្មដាច់ដោយឡែកនោះបានទេ ។

(គ) តម្លៃសមស្របនៃទ្រព្យវិនិយោគ មិនរួមបញ្ចូលនូវ ចំណូលពីការបង់មុន ឬចំណូលពីប្រតិបត្តិការបង្គរ ពីព្រោះអង្គភាពទទួលស្គាល់វាជាបំណុលដោយឡែក ឬក៏ទ្រព្យសកម្ម ។

(ឃ) តម្លៃសមស្របនៃទ្រព្យវិនិយោគ ដែលស្ថិតនៅក្រោមភតិសន្យា បង្ហាញពីលំហូរសាច់ប្រាក់រំពឹងទុក (រួមទាំងការជួលជាយថាហេតុដែលសង្ឃឹមថានឹងក្លាយជាបំណុល )។ ដូច្នេះ ប្រសិនបើការវាយតម្លៃទទួលបានសម្រាប់ទ្រព្យ គឺជាតំលៃមួយបន្ទាប់ពីការទូទាត់ដែលរំពឹងថានឹងត្រូវធ្វើឡើងវាមានភាពចាំបាច់ដើម្បីបូកត្រឡប់មកវិញនូវបំណុលសតិសន្យាដែលបានទទួលស្គាល់រួចមកហើយ ដើម្បីឱ្យបានតម្លៃយោងនៃទ្រព្យវិនិយោគកដោយប្រើវិធីសាស្ត្រតំលៃសមស្រប ។

៥១ តម្លៃសមស្របនៃទ្រព្យវិនិយោគមិនឆ្លុះបញ្ចាំងនូវចំណាយមូលធននៅពេល អនាគត ដែលនឹងធ្វើឱ្យប្រសើរឡើងនៃទ្រព្យ និងមិនឆ្លុះបញ្ចាំងអំពីផលប្រយោជន៍ពាក់ព័ន្ធនាពេលអនាគត ដែលកើតចេញពីចំណាយអនាគត ។

៥២ នៅក្នុងករណីខ្លះ អង្គភាពមួយសង្ឃឹមថា តម្លៃបច្ចុប្បន្ននៃការទូទាត់របស់វាដែលពាក់ព័ន្ធទៅនឹងទ្រព្យវិនិយោគ (លើកលែងតែការទូទាត់ដែលពាក់ព័ន្ធទៅនឹងបំណុលដែលបានទទួលស្គាល់រួចមកហើយ ) នឹងលើសពីតម្លៃបច្ចុប្បន្ន នៃចំណូលជាសាច់ប្រាក់ទាក់ទិន។ អង្គភាពមួយ អាចអនុវត្ត

ស.គ.អ.ក៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ដើម្បីកំណត់ថាតើត្រូវទទួលស្គាល់បំណុលនិងប្រសិនបើដូច្នេះមែនតើត្រូវវាស់វែងវា យ៉ាងដូចម្តេច?

**អលទ្ធភាពដើម្បីកំណត់តម្លៃសមស្របដោយជឿជាក់បាន**

៥៣ មានការសន្មតជាមុនដែលអាចច្រានចោលបានថា អង្គភាពមួយ អាចកំណត់នូវតម្លៃសមស្របនៃទ្រព្យវិនិយោគ លើមូលដ្ឋានបន្ត។ ទោះបីយ៉ាងណាក្នុងករណីពិសេសខ្លះ មានភស្តុតាងច្បាស់លាស់ នៅពេលដែលអង្គភាពមួយទិញទ្រព្យវិនិយោគជាលើកដំបូង (ឬនៅពេលទ្រព្យដែលមានស្រាប់នោះ បានក្លាយជាទ្រព្យវិនិយោគ បន្ទាប់ពីការសាងសង់ចប់ ឬ ក្រោយពីមានការប្រែប្រួលក្នុងការប្រើប្រាស់) តម្លៃសមស្របនៃទ្រព្យវិនិយោគមិនអាចកំណត់គួរឱ្យជឿជាក់បានឡើយ  ដោយឈរលើមូលដ្ឋានបន្តនេះ ។ ករណីនេះ កើតឡើងនៅពេលដែលប្រតិបត្តិការទីផ្សារ ប្រហាក់ប្រហែលនេះ កើតឡើងមិនទៀងទាត់ ហើយការប៉ាន់ស្មាននៃតម្លៃសមស្របតាមវិធីផ្សេងទៀត (ឧ. ផ្អែកលើ គំរោងការអប្បហារលំហូរសាច់ប្រាក់) មិនអាចអនុវត្តបាន។ ប្រសិនបើអង្គភាពមួយកំណត់ថាតំលៃសមស្របរបស់ទ្រព្យអាចកំណត់បានដោយជឿជាក់នៅពេលការសាងសង់ត្រូវបានបញ្ចប់ អង្គភាពត្រូវវាស់វែងទ្រព្យវិនិយោគនោះស្ថិតក្នុងការសាងសង់តាមថ្លៃដើមរហូតដល់តំលៃសមស្របត្រូវបានគេអាចកំណត់ដោយជឿជាក់ ឬការសាងសង់ត្រូវបានបញ្ចប់ (មួយណាមុនក៏បាន) ។ ប្រសិនបើអង្គភាពមួយកំណត់ថាតំលៃសមស្របនៃទ្រព្យវិនិយោគមួយ (ជាជាងទ្រព្យវិនិយោគស្ថិតក្នុងការសាងសង់) មិន

**អាចត្រូវបានវាស់វែងដោយជឿជាក់តាមមូលដ្ឋានបន្តទេនោះ អង្គភាពត្រូវវាស់វែងទ្រព្យវិនិយោគនោះដោយប្រើវិធីសាស្ត្រថ្លៃដើម ដូចមាននៅក្នុង ស.គ.អ.ក ១៦ ។ តំលៃកាកសំណល់នៃទ្រព្យវិនិយោគត្រូវបានសន្មតថាសូន្យ។ អង្គភាពត្រូវប្រើ ស.គ.អ.ក ១៦ រហូតដល់ការលក់ចោលនៃទ្រព្យវិនិយោគ។**

៥៣ក នៅពេលដែលអង្គភាពមួយអាចមានលទ្ធភាពវាស់វែងដោយជឿជាក់ពីតំលៃសបស្របនៃតំលៃ ទ្រព្យវិនិយោគដែលកំពុងសាងសង់ដែលពីគ្រាមុន ត្រូវបានវាស់វែងតាមថ្លៃដើម នោះអង្គភាពត្រូវវាស់វែងទ្រព្យសកម្មនោះតាមតំលៃសមស្របរបស់វា ។ នៅពេលដែលការសាងសង់នៃទ្រព្យនោះជាប់ជាស្ថានពរ ទ្រព្យនោះត្រូវបានសន្មតថាតំលៃសមស្របអាចត្រូវបានវាស់វែងដោយ ជឿជាក់។ ប្រសិនបើនេះមែនជាករណីទេនោះដោយអនុលោមតាមកថាខណ្ឌ ៥៣ នោះទ្រព្យត្រូវបានធ្វើគណនេយ្យកម្មដោយប្រើវិធីសាស្ត្រថ្លៃដើមដោយអនុលោមតាម ស.គ.អ.ក ១៦។

៥៣ខ ការសន្មតដែលតំលៃសមស្របនៃទ្រព្យវិនិយោគស្ថិតកំពុងសាងសង់អាចត្រូវបានវាស់វែងដោយជឿជាក់ អាចត្រូវបានគេច្រាលចោលតែនៅពេលទទួលស្គាល់ជាលើកដំបូង។ អង្គភាពមួយដែលបានវាស់វែងធាតុមួយនៃទ្រព្យវិនិយោគស្ថិតក្នុងការសាងសង់តាមតំលៃសមស្របមិនអាចដកចេញបានទេដែលតំលៃសមស្របនៃទ្រព្យវិនិយោគដែលបានបញ្ចប់មិនអាចត្រូវបានកំណត់ ដោយជឿជាក់។

៥៤ ករណីលើកលែងនៅពេលដែលអង្គភាពមួយត្រូវបានបង្ខំ សម្រាប់ហេតុផលដែលបានផ្តល់នៅក្នុងកថាខណ្ឌមុន ឱ្យមានការវាស់វែងទ្រព្យវិនិយោគ

មួយ ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើម យោងទៅតាម ស.គ.អ.ក ១៦ អង្គភាពនោះ ត្រូវតែវាស់វែងរាល់ទ្រព្យវិនិយោគដទៃទៀត តាមតម្លៃសមស្រប ។ ក្នុងករណីនេះ ទោះបីជាអង្គភាពនោះ អាចប្រើប្រាស់វិធីសាស្ត្រថ្លៃដើម សម្រាប់ទ្រព្យវិនិយោគមួយបានក៏ដោយ ក៏អង្គភាពនោះត្រូវបន្តអនុវត្តចំពោះ ទ្រព្យវិនិយោគផ្សេងទៀតដែលនៅសល់ ដោយប្រើប្រាស់វិធីសាស្ត្រ តម្លៃសមស្រប ។

៥៥ ប្រសិនបើអង្គភាពមួយ បានវាស់វែងទ្រព្យវិនិយោគតាមតម្លៃសមស្របពីមុនៗមក គេគួរបន្តវាស់វែងនូវ តម្លៃនៃទ្រព្យនោះ រហូតដល់ពេលដែលវាត្រូវបានលក់បញ្ចេញ (ឬ រហូតដល់ទ្រព្យនោះ មានម្ចាស់កាន់ កាប់ ឬ អង្គភាពចាប់ផ្តើមកែលំអទ្រព្យ ដើម្បីលក់ក្នុងប្រតិបត្តិការអាជីវកម្មធម្មតា) ទោះបីប្រតិបត្តិការ ទីផ្សារប្រហាក់ប្រហែលនោះ មានការថយចុះ ឬតម្លៃសមស្របពិបាកប្រមូលបានក៏ដោយ។

## វិធីសាស្ត្រថ្លៃដើម

៥៦ បន្ទាប់ពីការទទួលស្គាល់ជាដំបូង អង្គភាពមួយដែលជ្រើសរើសនូវវិធីសាស្ត្រថ្លៃដើម ត្រូវវាស់វែងគ្រប់ទ្រព្យ វិនិយោគទាំងអស់ ដោយអនុលោមតាមសេចក្តីតម្រូវនានានៃ ស.គ.អ.ក ១៦ សម្រាប់វិធីសាស្ត្រនោះ ជាជាងជ្រើសរើសដែលបំពេញលក្ខណៈវិនិច្ឆ័យដែលត្រូវចាត់ថ្នាក់ជាទ្រព្យវិនិយោគសម្រាប់ការលក់ (ឬ ត្រូវបានបញ្ចូលក្នុងក្រុមលក់ ដែលបានត្រូវចាត់ថ្នាក់សម្រាប់លក់) ដោយយោងទៅតាម ស.រ.ហ.អ.ក ៥ *ទ្រព្យសកម្មរយៈពេលវែងសម្រាប់លក់ និងកិច្ចប្រតិបត្តិការមិនបន្ត*)។ ទ្រព្យវិនិយោគដែលបំពេញ

លក្ខណៈវិនិច្ឆ័យ គ្រប់គ្រាន់ដើម្បីចាត់ថ្នាក់សម្រាប់លក់ (ឬត្រូវបានបញ្ចូលក្នុងក្រុម ដើម្បីចាត់ថ្នាក់សម្រាប់លក់) នឹងត្រូវបានគណនាដោយយោងតាម ស.រ.ហ.អ.ក ៥។

## ការផ្ទេរ

៥៧ ការផ្ទេរទៅ ឬផ្ទេរមកទ្រព្យវិនិយោគ ត្រូវធ្វើឡើងនៅពេលដែល និងតែម្តង នៅពេលមានការផ្លាស់ប្តូរ ក្នុងការប្រើប្រាស់ដែលបង្ហាញដោយ ÷

(ក) ការចាប់ផ្តើមដោយម្ចាស់កម្មសិទ្ធិ សម្រាប់ប្តូរមកពីទ្រព្យវិនិយោគ ទៅជាទ្រព្យកាន់កាប់ដោយម្ចាស់

(ខ) ការចាប់ផ្តើមការអភិវឌ្ឍក្នុងគោលបំណងលក់ សម្រាប់ការប្តូរពីទ្រព្យវិនិយោគទៅជាសន្និធិ

(គ) នៅពេលបញ្ចប់ការកាន់កាប់ដោយម្ចាស់ ចំពោះការផ្ទេរពីទ្រព្យកាន់កាប់ដោយម្ចាស់ទៅទ្រព្យវិនិយោគ។

(ឃ) ការចាប់ផ្តើមនៃភតិសន្យាប្រតិបត្តិការទៅឱ្យភាគីមួយផ្សេងទៀត ចំពោះការផ្ទេរទ្រព្យពីសន្និធិ ទៅទ្រព្យវិនិយោគ ។

(ង) [លុបចោល]

៥៨ កថាខណ្ឌ ៥៧ (ខ) តម្រូវឱ្យអង្គភាពផ្ទេរទ្រព្យពីទ្រព្យវិនិយោគទៅជាសន្និធិនៅពេល និងតែនៅពេលមានការ ផ្លាស់ប្តូរក្នុងការប្រើប្រាស់ដែលបង្ហាញដោយការចាប់ផ្តើមអភិវឌ្ឍន៍ ក្នុងគោលបំណងសម្រាប់លក់រហូតដល់ គេលែងទទួលស្គាល់វា (ត្រូវលុបចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ) និងមិនចាត់ទុកជាសន្និធិ ។ ករណីដូចគ្នា ប្រសិនបើអង្គភាពមួយចាប់ផ្តើមធ្វើការអភិវឌ្ឍឡើងវិញនូវទ្រព្យដែលមានស្រាប់ ដើម្បីបន្ត

ប្រើប្រាស់ទៅមុខទៀតធ្វើជាទ្រព្យវិនិយោគទ្រព្យនោះនៅតែជាទ្រព្យវិនិ-យោគ និងមិនត្រូវបានចំណាត់ថ្នាក់ឡើងវិញជាទ្រព្យកាន់កាប់ដោយម្ចាស់ក្នុងអំឡុងពេលអភិវឌ្ឍឡើងវិញនោះទេ ។

៥៩ កថាខណ្ឌ ៦០-៦៥ អនុវត្តចំពោះបញ្ហានៃការវាស់វែង និងការទទួលស្គាល់ដែលកើតឡើងនៅពេល អង្គភាពមួយ ប្រើប្រាស់វិធីសាស្ត្រតំលៃសមស្របសម្រាប់ទ្រព្យវិនិយោគ។ នៅពេលដែលអង្គភាពមួយ ប្រើប្រាស់វិធីសាស្ត្រថ្លៃដើម ការផ្ទេររវាងទ្រព្យវិនិយោគ ទ្រព្យកាន់កាប់ដោយម្ចាស់ និងសន្និធិមិនមាន ការផ្លាស់ប្តូរតម្លៃយោងនៃទ្រព្យដែលបានផ្ទេរ និងក៏មិនផ្លាស់ប្តូរថ្លៃដើមនៃទ្រព្យទាំងនោះ សម្រាប់គោលបំណងបង្ហាញព័ត៌មាន និងការវាស់វែង ។

**៦០ ការផ្ទេរពីទ្រព្យវិនិយោគ ដែលកត់ត្រាតាមតម្លៃសមស្រប ទៅជាទ្រព្យកាន់កាប់ដោយម្ចាស់ ឬសន្និធិ ថ្លៃដើមជំនួសនៃទ្រព្យសម្រាប់ការិយបរិច្ឆេទគណនេយ្យបន្ទាប់ ដោយយោងតាម ស.គ.អ.ក ១៦ ឬក៏ ស.គ.អ.ក ២ ត្រូវតែជាតម្លៃសមស្រប នៅថ្ងៃនៃការផ្លាស់ប្តូរការប្រើប្រាស់ ។**

**៦១ ប្រសិនបើទ្រព្យកាន់កាប់ដោយម្ចាស់ ក្លាយជាទ្រព្យវិនិយោគដែលនឹងត្រូវប្រើប្រាស់តម្លៃសមស្រប អង្គភាពមួយត្រូវអនុវត្ត ស.គ.អ.ក ១៦ រហូតដល់ថ្ងៃដែលមានការផ្លាស់ប្តូរការប្រើប្រាស់។ អង្គភាពចាត់ទុកថា ភាពខុសគ្នាណាមួយនៅកាលបរិច្ឆេទនោះ រវាងតម្លៃយោងនៃទ្រព្យ យោងតាម ស.គ.អ.ក ១៦ និង តម្លៃសមស្របរបស់វា នៅក្នុងវិធីដូចគ្នាទៅនឹងការវាយ តម្លៃឡើងវិញ យោងតាម ស.គ.អ.ក ១៦ ។**

៦២ រហូតដល់កាលបរិច្ឆេទ នៅពេលទ្រព្យកាន់កាប់ដោយម្ចាស់បានក្លាយជាទ្រព្យវិនិយោគ ដែលកត់ត្រាតាមតម្លៃសមស្រប អង្គភាពត្រូវធ្វើរំលស់ទ្រព្យនោះ និងទទួលស្គាល់ការខាតបង់ពីការធ្លាក់ចុះតំលៃណាមួយដែលបានកើតឡើង ។ អង្គភាពត្រូវចាត់ទុកថា ភាពខុសគ្នាណាមួយនៅកាលបរិច្ឆេទនោះ រវាងតម្លៃយោង នៃទ្រព្យយោងតាម ស.គ.អ.ក ១៦ និងតម្លៃសមស្របរបស់វា នៅក្នុងវិធីដូចគ្នាទៅនឹងការវាយតម្លៃឡើងវិញ យោងតាម ស.គ.អ.ក ១៦ ។ និយាយម្យ៉ាងទៀត ÷

(ក) លទ្ធផលថយចុះណាមួយ ក្នុងតម្លៃយោងនៃទ្រព្យ ត្រូវទទួលស្គាល់ជាចំណេញ-ខាត។ ប៉ុន្តែប្រសិនបើអង្គភាពនោះ មានទំហំទឹកប្រាក់ដែលបានកត់បញ្ចូលទៅក្នុងគណនីការអតិរេកពីការវាយតំលៃសម្រាប់ទ្រព្យនោះ ការថយចុះនេះ នឹងត្រូវធ្វើការកត់ត្រាផ្ទុយ ពីគណនីអតិរេកពីការវាយតំលៃនៅក្នុងដើមទុន។

(ខ) លទ្ធផលកើនឡើងណាមួយនៃតម្លៃយោង ត្រូវបានគិតដូចខាងក្រោម ÷

១- ទំហំនៃការកើនឡើងបញ្រ្ចាស់នូវការខាតបង់ពីមុនសម្រាប់ទ្រព្យ ការកើនឡើងនោះ ត្រូវបានទទួលស្គាល់ជាចំណេញ-ខាត។ ចំនួនទឹកប្រាក់ត្រូវទទួលស្គាល់ជាចំណេញ-ខាត មិនត្រូវលើស ពីទឹកប្រាក់ត្រូវការចាំបាច់ដើម្បីតំឡើងតម្លៃយោងនៅត្រឹមតម្លៃមួយដែលអាចកំណត់បាន ប្រសិនបើគ្មានការខាតបង់តម្លៃត្រូវបានទទួលស្គាល់ នោះទេ ។

២- ផ្នែកដែលនៅសល់នៃការកើនឡើង ត្រូវបានកត់ត្រាឥណទាន ដោយផ្ទាល់នៃមូលធន ក្នុងគណនីអតិរេកនៃការវាយតម្លៃឡើងវិញ។ នៅពេលដែលក្រោយមកទៀតមានការ លក់បញ្ចេញនៃទ្រព្យវិនិយោគ តម្លៃអតិរេកនៃការវាយតម្លៃឡើងវិញ ដែលមាននៅក្នុងគណនីមូលធនត្រូវផ្ទេរទៅគណនីប្រាក់ចំណេញរក្សាទុក ។ ការផ្ទេរពីអតិរេកដែល វាយតម្លៃឡើងវិញ ទៅប្រាក់ចំណេញរក្សាទុក មិនឆ្លងកាត់ចំណេញឬខាតឡើយ។

**៦៣ ការផ្ទេរពីសន្និធិទៅទ្រព្យវិនិយោគដែលបានអនុវត្តតម្លៃសមស្រប ភាពខុសគ្នាណាមួយ រវាងតម្លៃសមស្រប នៃទ្រព្យនៅពេលនោះ និងតម្លៃយោងដែលបានអនុវត្តលើកមុន នឹងត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។**

៦៤ ការទទួលស្គាល់នៃការផ្ទេរពីសន្និធិ ទៅទ្រព្យវិនិយោគដែលអនុវត្តតាមតម្លៃសមស្រប ដែលមានសង្គតិភាពជាមួយនឹងការទទួលស្គាល់ចំពោះការលក់សន្និធិដែរ។

**៦៥ នៅពេលដែលអង្គភាពមួយបានបំពេញចប់ការសាងសង់ ឬការអភិវឌ្ឍនៃទ្រព្យវិនិយោគសាងសង់ ផ្ទាល់ខ្លួន ដែលនឹងត្រូវបានអនុវត្តទៅតាមតម្លៃសមស្របការខុសគ្នាណាមួយរវាងតម្លៃសមស្របនៃទ្រព្យនៅកាវិយបរិច្ឆេទនោះនិងចំនួនតម្លៃយោងលើកមុននឹងត្រូវទទួលស្គាល់ជាចំណេញ- ខាត។**

**៦៦ ទ្រព្យវិនិយោគមួយនឹងត្រូវឈប់ទទួលស្គាល់វិញ (លុបបំបាត់ពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ) នៅពេលលក់ចេញ ឬនៅពេលដែលទ្រព្យវិនិយោគត្រូវបានដកចេញទាំងស្រុងពីការប្រើប្រាស់ និងគ្មានផលប្រយោជន៍ខាងសេដ្ឋកិច្ចនាពេលអនាគត ត្រូវបានសង្ឃឹមទុកពីការលក់របស់ទ្រព្យនោះទេ។**

៦៧ ការលក់បញ្ចេញនៃទ្រព្យវិនិយោគ អាចទទួលបានដោយការលក់នៅលើទីផ្សារ ឬដោយភតិសន្យាហិរញ្ញវត្ថុ។ ការកំណត់កាលបរិច្ឆេទនៃការលក់ទ្រព្យ អង្គភាពមួយត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យ ស.គ.អ.ក ១៨ សម្រាប់ការទទួលស្គាល់ចំណូលដែលបានមកពីលក់ទំនិញ និងពិចារណាអំពីសេចក្តីណែនាំពាក់ពន្ធ័នៅក្នុងឧទាហរណ៍គំរូដែលមាននៅក្នុងស.គ.អ.ក ១៨ ។ ស.គ.អ.ក ១៧ អនុវត្តចំពោះការលក់បញ្ចេញតាមរយៈភតិសន្យាហិរញ្ញវត្ថុ និងចំពោះការលក់ និងការជួលត្រឡប់មកវិញ។

៦៨ ដោយយោងតាមគោលការណ៍ទទួលស្គាល់នៅក្នុងកថាខណ្ឌ ១៦ ប្រសិនបើអង្គភាពមួយ ទទួលស្គាល់នូវតម្លៃយោងនៃថ្លៃដើមទ្រព្យសកម្មមួយថ្លៃដើមជំនួសដោយផ្នែកមួយនៃទ្រព្យវិនិយោគនៃទ្រព្យសកម្មមួយ អង្គភាពនោះ ត្រូវឈប់ទទួលស្គាល់តម្លៃយោងនៃផ្នែកដែលបានជំនួសនោះវិញ។ សម្រាប់ទ្រព្យវិនិយោគដែលប្រើប្រាស់វិធីសាស្ត្រថ្លៃដើម ផ្នែកដែលបានជំនួសនោះ អាចនឹងមិនមែនជា ផ្នែកមួយដែលត្រូវធ្វើរំលស់ដាច់ដោយឡែកពីគ្នានោះទេ។ ប្រសិនបើមិនអាចអនុវត្តបានសម្រាប់អង្គភាពមួយក្នុងការកំណត់នូវតម្លៃយោងនៃផ្នែកដែលបានជំនួស គេអាចប្រើប្រាស់ថ្លៃដើមនៃការជំនួសនោះ ជាការបង្ហាញនូវថ្លៃដើមនៃផ្នែកដែលបានជំនួសនៅ

ការិយបរិច្ឆេទដែលវាបានទិញឬសាងសង់។ក្រោមវិធីសាស្ត្រតម្លៃសមស្រប តម្លៃសមស្របនៃទ្រព្យវិនិយោគ អាចបង្ហាញរួចជាស្រេចហើយថា ផ្នែកដែល នឹងត្រូវជំនួសបានបាត់បង់តម្លៃរបស់វារួចទៅហើយ ។ នៅក្នុងករណីខ្លះទៀត វាអាចមានភាពលំបាកដឹងថា តើតម្លៃសមស្របត្រូវបានកាត់បន្ថយចំនួនប៉ុន្មាន ចេញពីផ្នែកដែលត្រូវជំនួសនោះ ។ ជម្រើសមួយទៀត ដើម្បីកាត់បន្ថយតម្លៃសមស្រប សម្រាប់ផ្នែកបានជំនួស (នៅពេលមិនអាចអនុវត្តបាន) គឺត្រូវបញ្ចូលតម្លៃនៃការជំនួស ក្នុងតម្លៃយោងនៃទ្រព្យសកម្ម និងបន្ទាប់មក ត្រូវវាយតម្លៃឡើងវិញតាមតម្លៃសមស្របនោះ ដូចដែលបានធ្វើឡើងសម្រាប់ការបន្ថែមទ្រព្យដែលមិនជាប់ពាក់ព័ន្ធនឹងការជំនួសនោះ ។

**៦៩ ចំណេញឬខាតកើតឡើងពីការចូលនិវត្តន៍ ឬ លក់បញ្ចេញនៃទ្រព្យវិនិយោគ នឹងត្រូវកំណត់ថា ជាភាពខុសគ្នារវាង ទឹកប្រាក់លក់បានពិត និងតម្លៃយោងនៃទ្រព្យសកម្មនោះ និងត្រូវទទួលស្គាល់ជា ចំណេញឬខាត (លើកលែង តែ ស.គ.អ.ក ១៧ តម្រូវផ្សេងពីនោះ លើការលក់ និងជួលត្រឡប់មកវិញ ) ក្នុងការិយបរិច្ឆេទនៃការចូលនិវត្តន៍ ឬ ការលក់បញ្ចេញនោះ ។**

៧០ តម្លៃតបស្នងដែលត្រូវទទួលពីការលក់បញ្ចេញទ្រព្យវិនិយោគ ត្រូវបានទទួលស្គាល់គ្រាដំបូងជាតម្លៃសមស្រប ។ ជាពិសេស ប្រសិនការទូទាត់នៃទ្រព្យវិនិយោគ ត្រូវបានពន្យាពេល តម្លៃតបស្នងដែលទទួលបាន គឺជាត្រូវទទួលស្គាល់ជាលើកដំបូងតាមតម្លៃសាច់ប្រាក់សមមូល ។ ភាពខុសគ្នារវាងចំនួនទឹកប្រាក់មានតែនាមនៃតម្លៃតបស្នង និងតម្លៃសាច់ប្រាក់សមមូលត្រូវ

បានទទួលស្គាល់ជាចំណូលការប្រាក់ដោយយោងតាម ស.គ.អ.ក ១៨ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ។

៧១ អង្គភាពមួយអនុវត្ត ស.គ.អ.ក ៣៧ ឬស្តង់ដាដទៃទៀត ដែលសមស្រប ចំពោះបំណុលណាមួយដែលគេនៅជំពាក់បន្ទាប់ពីលក់បញ្ចេញនៃទ្រព្យ-វិនិយោគនោះ។

**៧២ ការសងជំងឺចិត្តពីភាគីទីបី សម្រាប់ទ្រព្យវិនិយោគដែលបានធ្លាក់ចុះតំលៃបាត់បង់ ឬបោះបង់ចោលនឹងត្រូវទទួលស្គាល់ជាចំណេញ ឬខាត នៅពេលដែលការសងជំងឺចិត្តនោះរំពឹងថា ទទួលបានពីអតិថិជន ។**

៧៣ ការចុះថយតម្លៃ ឬការខាតនៃទ្រព្យវិនិយោគ ការទាមទារពាក់ព័ន្ធ ឬការសងជាសាច់ប្រាក់ ពាក់ព័ន្ធ សំណងជំងឺចិត្តពីភាគីទីបី និងការទិញសង ឬការសាងសង់សងនៃទ្រព្យសកម្មជំនួសពេលបន្ទាប់មកទៀតគឺជាព្រឹត្តិការណ៍សេដ្ឋកិច្ចដាច់ដោយឡែកពីគ្នា ហើយត្រូវធ្វើគណនេយ្យកម្មដាច់ដោយឡែកពីគ្នាផងដែរ ដូចខាងក្រោម ÷

(ក) ការខូចខាតតម្លៃនៃទ្រព្យវិនិយោគ ត្រូវបានទទួលស្គាល់ដោយយោងតាម ស.គ.អ.ក ៣៦

(ខ) ការហួសកំណត់ ឬការលក់បញ្ចេញនៃទ្រព្យវិនិយោគ ត្រូវទទួលស្គាល់នៅក្នុងកថាខណ្ឌ ៦៦-៧១ នៃស្តង់ដានេះ ។

(គ) ការសងជំងឺចិត្តពីភាគីទីបីសម្រាប់ទ្រព្យវិនិយោគដែលបានខូចខាតតម្លៃបាត់បង់ ឬបោះបង់ចោល ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅពេលដែលរំពឹងថា ទទួលបានពីអតិថិជន និង

(ឃ) តម្លៃដើមនៃទ្រព្យសកម្ម ដែលបានស្តារឡើងវិញទិញ ឬសាងសង់ជាទ្រព្យជំនួស ត្រូវបានកំណត់ ដោយអនុលោមតាម កថាខណ្ឌ ២០-២៩ នៃស្តង់ដានេះ។

## ការលាតត្រដាងព័ត៌មាន

### វិធីសាស្ត្រតម្លៃសមស្រប និង ថ្លៃដើម

៧៤ ការលាតត្រដាងព័ត៌មាន អនុវត្តបន្ថែមទៅនឹងការបង្ហាញផ្សេងទៀត ក្នុង ស.គ.អ.ក ១៧ ។ អនុលោមតាម ស.គ.អ.ក ១៧ ម្ចាស់កម្មសិទ្ធិនៃទ្រព្យវិនិយោគ លាតត្រដាងព័ត៌មានជាម្ចាស់ភតិកៈអំពីការជួលដែលគេបានធ្វើឡើង ។ អង្គភាពដែលកាន់កាប់ទ្រព្យវិនិយោគក្រោមភតិសន្យាហិរញ្ញវត្ថុ ឬប្រតិបត្តិការ ត្រូវផ្តល់ព័ត៌មានឱ្យភតិកៈ សម្រាប់ភតិសន្យាហិរញ្ញវត្ថុ និងបង្ហាញជាម្ចាស់ភតិកៈ សម្រាប់ភតិសន្យា ប្រតិបត្តិការណាមួយ ដែលគេធ្វើឡើង ។

**៧៥ អង្គភាពមួយត្រូវលាតត្រដាង ÷**

**(ក) ថាតើគេអនុវត្តវិធីសាស្ត្រតម្លៃសមស្រប ឬ ថ្លៃដើម**

**(ខ) ប្រសិនបើគេអនុវត្តវិធីសាស្ត្រតម្លៃសមស្រប ថាតើនិងនៅក្នុងកាលៈទេសៈណា ភាគកម្មនៃទ្រព្យក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានចំណាត់ថ្នាក់ និងគណនេយ្យកម្មជាទ្រព្យវិនិយោគ ។**

**(គ) នៅពេលដែលចំណាត់ថ្នាក់មានការពិបាក (មើលកថាខណ្ឌ ១៤) លក្ខណៈវិនិច្ឆ័យដែលគេប្រើ ដើម្បីបង្ហាញពីភាពខុសគ្នា អំពី**

ទ្រព្យវិនិយោគពីទ្រព្យកាន់កាប់ដោយម្ចាស់ និងពីទ្រព្យសម្រាប់លក់ នៅក្នុងប្រតិបត្តិការធម្មតាអាជីវកម្ម។

(ឃ) វិធីសាស្ត្រ និងការសន្មតចាំបាច់ទាំងឡាយ ដែលប្រើក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យវិនិយោគ រួមទាំងសេចក្ដីថែងថាតើការកំណត់នៃតម្លៃសមស្រប ត្រូវបានគាំទ្រដោយមានភស្តុតាងពីទីផ្សារ ឬមានមូលដ្ឋាន លើកត្តាផ្សេងៗទៀត (ដែលអង្គភាពត្រូវលាតត្រដាង) ដោយសារប្រភេទនៃទ្រព្យ និងភាពគ្មាន ទិន្នន័យទីផ្សារសម្រាប់ប្រៀបធៀប ។

(ង) វិសាលភាពដែលតម្លៃសមស្របណាមួយនៃទ្រព្យវិនិយោគ (ដូចដែលវាស់វែង ឬបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) បានផ្អែកលើការវាយតម្លៃ ដោយអ្នកវាយតម្លៃឯករាជ្យដែលមានការ ទទួលស្គាល់ និងមានវិជ្ជាជីវៈច្បាស់លាស់ និងមានបទ-ពិសោធន៍ថ្មីៗនៅក្នុងទីតាំង និងប្រភេទនៃទ្រព្យវិនិយោគដែលត្រូវបានវាយតម្លៃ។ ប្រសិនបើគ្មានការវាយតម្លៃដូច្នេះទេ ត្រូវតែបង្ហាញសាច់រឿង អំពីមូលហេតុដែលមិនអាចធ្វើការវាយតម្លៃបាន។

(ច) ទទួលស្គាល់ទឹកប្រាក់នៅក្នុងរបាយការណ៍លទ្ធផល សម្រាប់ ÷

(១) ចំណូលពីការជួលដែលបានមកពីទ្រព្យវិនិយោគ

(២) ការចំណាយប្រតិបត្តិការផ្ទាល់ (រួមទាំងការជួសជុលនិងថែរក្សា) កើតឡើងពីការ វិនិយោគទ្រព្យដែល ផលិតចំណូលពីការជួលក្នុងការិយបរិច្ឆេទ និង

(៣) ការចំណាយប្រតិបត្តិការផ្ទាល់ (រួមទាំងការជួសជុល និងថែរក្សា) កើតឡើងពីការវិទ្រព្យនិយោគ ដែលមិនផលិតចំណូលពីការជួលក្នុងការិយបរិច្ឆេទ

(៤) ទឹកប្រាក់បង្គរនៃការផ្លាស់ប្តូរតម្លៃសមស្របដែលបានទទួលស្គាល់ក្នុងរបាយការណ៍ ចំណេញ ឬខាតក្នុងការលក់ទ្រព្យ វិនិយោគដែលបានមកពីបណ្តុំនៃទ្រព្យសកម្ម នៅពេលដែល ប្រើប្រាស់វិធិសាស្រ្តថ្លៃដើម ត្រូវបានប្រើប្រាស់ក្នុងបណ្តុំ នៅពេលដែលវិធីសាស្រ្ត តម្លៃសមស្របត្រូវបានប្រើ (មើលកថាខណ្ឌ ៣២ គ)។

(ង) អត្ថិភាព និងទឹកប្រាក់កំហិតនៃការទទួលស្គាល់លើទ្រព្យវិនិយោគពិត ឬការទទួលបានចំណូល និងចំណូលពីការលក់។

(ជ) បំណុលតាមកិច្ចសន្យាដើម្បីទិញ សាងសង់ ឬអភិវឌ្ឍនិទ្រព្យវិនិយោគ ឬការជួសជុស ថែរក្សា ឬកែលម្អ។

## វិធីសាស្រ្តតម្លៃសមស្រប

៧៦ បន្ថែមទៅលើការលាតត្រដាងព័ត៌មាន តម្រូវដោយដោយកថាខណ្ឌ ៧៥ អង្គភាពមួយដែលប្រើប្រាស់វិធីសាស្រ្តតម្លៃសមស្រប នៅក្នុងកថាខណ្ឌ ៣៣-៥៥ ត្រូវធ្វើការលាតត្រដាងនូវការការសម្របសម្រួលរវាងតម្លៃយោងនៃទ្រព្យវិនិយោគ នៅដើមការិយបរិច្ឆេទនិងចុងការិយបរិច្ឆេទ ដោយលាតត្រដាងអំពី ÷

(ក)	ទ្រព្យបន្ថែម ដោយបង្ហាញដាច់ដោយឡែកនូវទ្រព្យបន្ថែមទាំងនោះ ដែលបានមកពីការទិញ និងពីការចំណាយមូលធនដែលបាន ទទួលស្គាល់ នៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម។

(ខ)	ទ្រព្យបន្ថែម ដែលទទួលបានតាមរយៈការទិញអាជីវកម្មបញ្ចូលគ្នា

(គ)	ទ្រព្យសកម្មដែលចាត់ថ្នាក់សម្រាប់លក់ ឬ បញ្ចូលទៅក្នុងក្រុមទ្រព្យ សម្រាប់លក់បញ្ចេញ ដែលចាត់ថ្នាក់សម្រាប់លក់ ដោយយោងតាម ស.រ.ហ.អ.ក ៥ និង ការលក់បញ្ចេញទ្រព្យដទៃទៀត។

(ឃ)	ចំណេញ ឬ ខាតពិត ពីកែសំរួលតម្លៃសមស្រប

(ង)	ភាពខុសគ្នាពិតនៃអត្រាប្តូរប្រាក់សុទ្ធ កើតឡើងក្នុងការបកប្រែនៃ របាយការណ៍ហិរញ្ញវត្ថុ ទៅជារូបិយវត្ថុសម្រាប់បង្ហាញ និងការបក ប្រែនៃប្រតិបត្តិការបរទេស ទៅជារូបិយប័ណ្ណបង្ហាញនៃអង្គភាព ដែលរាយការណ៍។

(ច)	ការផ្លាស់ប្តូរទៅ ឬផ្លាស់មកពីសន្និធិ និងទ្រព្យកាន់កាប់ដោយ ម្ចាស់ និង

(ឆ)	ការផ្លាស់ប្តូរផ្សេងៗទៀត

៧៧	នៅពេលការវាយតម្លៃទទួលបាន ចំពោះទ្រព្យវិនិយោគ ត្រូវបានកែសម្រួល សម្រាប់គោលបំណង នៃរបាយការណ៍ហិរញ្ញវត្ថុ ឧទាហរណ៍ ដើម្បីជៀស វាងការរាប់ទ្វេដងនៃទ្រព្យសកម្ម ឬ បំណុល ដែលត្រូវ បានទទួលស្គាល់ថា ជាទ្រព្យសកម្ម និងបំណុលដាច់ដោយឡែក ដូចបានពណ៌នានៅក្នុង កថាខណ្ឌ ៥០ នោះអង្គភាពត្រូវបង្ហាញការកែតម្រូវ រវាងការវាយតម្លៃដែល

ទទួលបាន និងតម្លៃកែសម្រួល ដែលបានបញ្ចូល ទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយបង្ហាញដាច់ពីគ្នា រវាងទឹកប្រាក់សរុបនៃបំណុលជួល ដែលបានយកត្រឡប់មកវិញ និងនិយ័តកម្មសំខាន់ផ្សេងៗទៀត ។

៧៨. ករណីពិសេសខ្លះ យោងតាមកថាខណ្ឌ ៥៣ នៅពេលដែលអង្គភាពមួយវាស់វែងទ្រព្យវិនិយោគ ដោយ ប្រើប្រាស់វិធីសាស្ត្រថ្លៃដើមក្នុង ស.គ.អ.ក ១៦ ការសម្របសម្រួលតម្រូវដោយកថាខណ្ឌ ៧៦ ត្រូវលាតត្រដាងនូវចំនួនទឹកប្រាក់ដែលទាក់ទងទៅនឹងទ្រព្យវិនិយោគដាច់ដោយឡែកពីចំនួនទឹកប្រាក់ដែលពាក់ព័ន្ធទៅនឹង ទ្រព្យវិនិយោគដទៃទៀត។ ក្រៅពីនេះអង្គភាពត្រូវលាតត្រដាង ÷

(ក) ការបរិយាយពីទ្រព្យវិនិយោគ

(ខ) ការពន្យល់ថា ហេតុអ្វីបានជាតម្លៃសមស្រប មិនអាចកំណត់បានដោយជឿជាក់

(គ) ប្រសិនបើអាច សូមធ្វើការប៉ាន់ស្មានតម្លៃសមស្រប ទំនងជានៅចន្លោះពីប៉ុន្មានទៅប៉ុន្មាន និង

(ឃ) នៅពេលលក់បញ្ចេញទ្រព្យវិនិយោគដែលមិនប្រើប្រាស់តម្លៃទីផ្សារៈ

(១) ប្រាប់ពីសាច់រឿងដែលថា អង្គភាពបានលក់ទ្រព្យវិនិយោគ ដោយមិនប្រើប្រាស់តម្លៃ ទីផ្សារ។

(២) ចំនួនទឹកប្រាក់តម្លៃយោងនៃទ្រព្យវិនិយោគ នៅពេលលក់ និង

(៣) ចំនួនទឹកប្រាក់ចំណេញ ឬ ខាតដែលបានទទួលស្គាល់ ។

វិធីសាស្ត្រថ្លៃដើម

៧៩ បន្ថែមទៅលើការលាតត្រដាង តម្រូវដោយកថាខណ្ឌ ៧៥ អង្គភាពមួយដែលប្រើប្រាស់វិធីសាស្ត្រថ្លៃដើម នៅក្នុង កថាខណ្ឌ ៥៦ នឹងត្រូវលាតត្រដាង ÷

(ក) វិធីសាស្ត្ររំលស់ដែលបានប្រើប្រាស់

(ខ) អាយុកាល ឬ ការប្រើប្រាស់អត្រារំលស់

(គ) តម្លៃយោងដុល និងរំលស់បង្គរកើនឡើង (រួមជាមួយការខូចខាតតម្លៃបង្គរ) នៅដើម និង ចុងការិយបរិច្ឆេទ ។

(ឃ) ការសម្របសម្រួលនៃតម្លៃយោងនៃទ្រព្យវិនិយោគនៅដើម និង ចុងការិយបរិច្ឆេទ ដោយបង្ហាញខាងក្រោម ÷

(១) ទ្រព្យបន្ថែម ដោយលាតត្រដាងដាច់ដោយឡែកនូវទ្រព្យបន្ថែមទាំងនោះ ដែលបានមកពីការទិញ និងបានមកពីចំណាយ បន្ទាប់មកដែលទទួលស្គាល់ជាទ្រព្យសកម្ម

(២) ទ្រព្យបន្ថែម ដែលបានមកពីការទិញអាជីវកម្មបញ្ចូលគ្នា

(៣) ទ្រព្យសកម្មដែលចាត់ថ្នាក់សម្រាប់លក់ ឬបញ្ចូលទៅក្នុងក្រុមទ្រព្យសម្រាប់លក់បញ្ចេញ ដែលចាត់ថ្នាក់សម្រាប់លក់ដោយយោងតាមស.រ.ហ.អ.ក ៥ និងការលក់ផ្សេងៗទៀត។

(៤) រំលស់

(៥) ទឹកប្រាក់នៃការខូចខាតតម្លៃដែលបានទទួលស្គាល់ និងទឹកប្រាក់ដែលខូចខាត ដែលបានយកត្រឡប់មកវិញក្នុងគ្រា ដោយយោងតាម ស.គ.អ.ក ៣៦

(៦) ភាពខុសគ្នានៃអត្រាប្តូរប្រាក់សុទ្ធ កើតឡើងក្នុងការបកប្រែនៃរបាយការណ៍ហិរញ្ញវត្ថុ ទៅជារូបិយវត្ថុសម្រាប់បង្ហាញ និងការបកប្រែនៃប្រតិបត្តិការបរទេស ទៅជាការបង្ហាញរូបិយប័ណ្ណនៃអង្គភាពដែលរាយការណ៍។

(៧) ការផ្លាស់ប្តូរពីសន្និធិទៅនឹងទ្រព្យកាន់កាប់ដោយម្ចាស់ និង

(៨) ការផ្លាស់ប្តូរដទៃទៀត និង

(ច) តម្លៃសមស្របនៃទ្រព្យវិនិយោគ។ ករណីពិសេសខ្លះ ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ៥៣ នៅពេលអង្គភាពមួយមិនអាចកំណត់តម្លៃសមស្របនៃទ្រព្យវិនិយោគ គេនឹងលាតត្រដាង ÷

(១) ការបរិយាយពីទ្រព្យវិនិយោគ

(២) ការពន្យល់ ហេតុអ្វីតម្លៃសមស្រប មិនអាចកំណត់បានដោយជឿជាក់ និង

(៣) ប្រសិនបើអាច សូមធ្វើការប៉ាន់ស្មានតម្លៃសមស្របទំនងជានៅចន្លោះពីប៉ុន្មានទៅប៉ុន្មាន ។

## វិធីសាស្ត្រតម្លៃសមស្រប

៨០. អង្គភាពមួយដែលបានប្រើប្រាស់វិធីសាស្ត្រតម្លៃសមស្របពីមុន ស.គ.អ.ក ៤០ (២០០០) និងបានជ្រើសរើស ជាលើកទីមួយ ដើម្បីចំណាត់ថ្នាក់ និងធ្វើគណនេយ្យកម្ម សម្រាប់ភាគកម្មទ្រព្យដែលអាចជ្រើសរើសខ្លះ ឬ ទាំងអស់ ថែរក្សាក្រោមភតិសន្យាប្រតិបត្តិការជាទ្រព្យវិនិយោគ ត្រូវទទួលស្គាល់នូវការប៉ះពាល់នៃការជ្រើសរើស នោះថាជាការធ្វើនិយ័តភាពចំពោះ សមតុល្យដើមគ្រា នៃគណនីប្រាក់ចំណេញរក្សាទុក សម្រាប់ការិយបរិច្ឆេទ ដែលការជ្រើសរើសនោះ ត្រូវបានធ្វើឡើងលើកដំបូង ។ បន្ថែមលើនេះទៀត ÷

(ក) ប្រសិនបើអង្គភាពបានលាតត្រដាងជាសាធារណៈពីលើកមុខ (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) នូវតម្លៃសមស្របនៃភាគកម្មទ្រព្យ ទាំងនោះ នៅដើមការិយបរិច្ឆេទដំបូង (ការកំណត់ដោយឈរលើមូលដ្ឋាន ដែលឆ្លើយតបទៅនឹងនិយមន័យនៃតម្លៃសមស្របនៅក្នុងកថាខណ្ឌ ៥ និងការណែនាំនៅក្នុង កថាខណ្ឌ ៣៦-៥២) អង្គភាពត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនតម្រូវឱ្យ ÷

(១) កែសំរួលនូវសមតុល្យដើមគ្រានៃគណនីប្រាក់ចំណេញរក្សាទុកសម្រាប់កាយរិបរិច្ឆេទ ដំបូងបំផុតដែលបានលាតត្រដាងតម្លៃសមស្របជាសាធារណៈ និង

(២) រាយការណ៍ឡើងវិញនូវព័តិមានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទទាំងនោះនិង

(ខ) ប្រសិនបើអង្គភាព មិនបានបង្ហាញព័ត៌មានជាសាធារណៈពីលើកមុនទេ ដូចបានពណ៌នាក្នុង (ក) គេមិនត្រូវបង្ហាញឡើងវិញនូវព័ត៌មានប្រៀបធៀបទៀតទេ និងត្រូវលាតត្រដាងពីសាច់រឿងទាំងនោះ ។

៨១ ស្តង់ដានេះតំរូវមានការទទួលស្គាល់ខុសពីការទទួលស្គាល់នៅក្នុង ស.គ.អ.ក ៨ ។ ស.គ.អ.ក ៨ តម្រូវឱ្យមានព័ត៌មានប្រៀបធៀបដែលត្រូវបង្ហាញឡើងវិញលុះត្រាតែការបង្ហាញឡើងវិញនោះ មិនអាចអនុវត្តបាន ។

៨២ នៅពេលដែលអង្គភាពមួយអនុវត្តស្តង់ដានេះដំបូង ការកែសំរួលចំពោះសមតុល្យដើមគ្រានៃគណនី ប្រាក់ចំណេញរក្សាទុក រួមមានការចំណាត់ថ្នាក់ជាថ្មី នៃចំនួនទឹកប្រាក់ នៅក្នុងគណនីអតិរេកនៃការវាយតម្លៃឡើងវិញសម្រាប់ទ្រព្យវិនិយោគ។

## វិធីសាស្ត្រថ្លៃដើម

៨៣ ស.គ.អ.ក ៨ អនុវត្តចំពោះការផ្លាស់ប្តូរគោលនយោបាយគណនេយ្យណាមួយដែលត្រូវបានធ្វើឡើង នៅពេល ដែលអង្គភាពនោះ បានអនុវត្តជាដំបូងនូវស្តង់ដានេះ និងជ្រើសរើសការប្រើប្រាស់វិធីសាស្ត្រថ្លៃដើមនេះ។ ការប៉ះពាល់នៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យនេះ រួមមានការចំណាត់ថ្នាក់ជាថ្មីនៃចំនួនទឹកប្រាក់ ក្នុងគណនីអតិរេកនៃការវាយតម្លៃឡើងវិញសម្រាប់ទ្រព្យវិនិយោគ ។

៨៤ ការតំរូវនៃកថាខណ្ឌ ២៧-២៩ ចំពោះ ការវាស់វែងដំបូងនៃទ្រព្យវិនិយោគ បានមកពីប្រតិបត្តិការដោះដូរទ្រព្យសកម្ម ត្រូវអនុវត្តនូវវិធីសាស្រ្តនិយ័ត-ភាពសម្រាប់អនាគតតែមួយគត់ ចំពោះប្រតិបត្តិការអនាគតទាំងអស់។

## ថ្ងៃចូលជាធរមាន

៨៥ អង្គភាពមួយ ត្រូវអនុវត្តស្តង់ដានេះ សម្រាប់ការិយបរិច្ឆេទ ប្រចាំឆ្នាំចាប់ផ្តើមថ្ងៃ ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត ។ ប្រសិនបើអង្គភាពមួយ អនុវត្តនូវស្តង់ដានេះ សម្រាប់ការិយបរិច្ឆេទដំបូង មុនថ្ងៃទី០១ ខែមករា ឆ្នាំ ២០០៥ ត្រូវបង្ហាញពីសាច់រឿងនោះ។

៨៥ក ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៧)*បានធ្វើវិសោធនកម្មវាក្យស័ព្ទដែលបានប្រើទូទាំង ស.រ.ហ.អ.ក។ លើសពីនេះ ស.គ.អ.ក ១ បានធ្វើ វិសោធនកម្មកថាខណ្ឌ៦២ ។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ ផ្តើមនៅថ្ងៃទី១ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០០៩។ ប្រសិនបើអង្គភាព មួយប្រើ ស.គ.ក.១ (បានកែប្រែ ឆ្នាំ២០០៧) សម្រាប់គ្រាមុន វិសោធនកម្ម ត្រូវបានប្រើសម្រាប់គ្រាមុននោះ។

៨៥ខ កថាខណ្ឌ ៨ ៩ និង ៤៨ និង ៥៣ និង ៥៧ ត្រូវបានធ្វើវិសោធនកម្ម កថាខណ្ឌ ២២ ត្រូវបានលុបចោល និង កថាខណ្ឌ ៥៣ក និង ៥៣ខ ត្រូវបានបន្ថែមដោយ*ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយខែឧសភាឆ្នាំ២០០៩ ។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្ម

ទាំងនោះទៅពេលខាងមុខសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម នៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩ ។ អង្គភាពមួយត្រូវបាន អនុញ្ញាតឱ្យអនុវត្តវិសោធនកម្ម ចំពោះទ្រព្យវិនិយោគដែលស្ថិតក្នុងការ សាងសង់ចាប់ពីថ្ងៃណាមួយក៏ដោយមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៩ ដោយ ដឹងថាតំលៃសមស្របនៃទ្រព្យវិនិយោគស្ថិតក្នុងការសាងសង់ត្រូវបាន កំណត់ នៅកាលបរិច្ឆេទទាំងនោះ។ ការអនុវត្តមុនត្រូវបានអនុញ្ញាតិ ។ ប្រសិនបើអង្គភាពមួយអនុវត្ត វិសោធនកម្មសម្រាប់គ្រាមុន អង្គភាពត្រូវ លាតត្រដាងពីសាច់រឿងនោះ និងព្រមពេលជាមួយគ្នា ត្រូវអនុវត្ត វិសោធនកម្មចំពោះកថាខណ្ឌ ៥ និង ៨១ង នៃ ស.គ.អ.ក ១៦ *ទ្រព្យ រោងចក្រ និង បរិក្ខារ។*

## ការដកចេញ ស.គ.អ.ក ៤០(២០០០)

៨៦ ស្តង់ដានេះជំនួស ស.គ.អ.ក ៤០*ទ្រព្យវិនិយោគ* (ចេញផ្សាយនៅក្នុង ឆ្នាំ២០០០)។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ